**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

**សំណុំរឿងលេខ:** ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

**ភាគីដាក់ឯកសារ:** សហមេធាវីរបស់ នួន ជា

**ដាក់ជូន:** អង្គជំនុំជម្រះសាលាដំបូង

**ភាសាដើម:** អង់គ្លេស

**កាលបរិច្ឆេទឯកសារ:** ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០១៦

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 23-May-2016, 11:28
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

**ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ:** សាធារណៈ

**ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង:** សាធារណៈ/Public

**ចំណាត់ថ្នាក់ប្រភេទឯកសារ:**

**ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:**

**ឈ្មោះមន្ត្រីកត់ត្រា:**

ហត្ថលេខា:

---

# សារណាតបរួមរបស់ នួន ជា ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីចំពោះសំណើរបស់ នួន ជា អនុលោមតាមវិធាន ៩២ នៃវិធានផ្ទៃក្នុង សុំប្រើប្រាស់ចម្លើយសារភាព ស-២១ មួយចំនួន

---

**ដាក់ដោយ÷**

**ក្រុមមេធាវីការពារក្តី នួន ជា**

សុន អរុណ

Victor KOPPE

លីវ សុវណ្ណា

Doreen CHEN

ព្រុំ ផល្លា

Xiaoyang NIE
Marina HAKKOU
Léa KULINOWSKI

ឌី សុជាតា

**ផ្ញើជូន÷**

**សហមេធាវីរបស់ ខៀវ សំផន**

គង់ សំអុន

Anta GUISSÉ

**សហព្រះរាជអាជ្ញា÷**

ជា លាង

Nicholas KOUMJIAN

**សហមេធាវី តំណាងដើមបណ្ដឹងរដ្ឋប្បវេណី**

ពេជ អង្គ

Marie GUIRAUD

## I. សេចក្ដីផ្ដើម

1. អនុលោមតាមវិធាន ៩២ នៃវិធានផ្ទៃក្នុង និងមាត្រា ៨.៤ នៃសេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារនៅ អ.វ.ត.ក សហមេធាវីរបស់លោក នួន ជា ("មេធាវីការពារក្ដី") សូមដាក់សារណាតបរួមនេះទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីចំពោះសំណើរបស់ នួន ជា អនុលោមតាមវិធាន ៩២ នៃវិធានផ្ទៃក្នុង សុំប្រើប្រាស់ចម្លើយសារភាព ស-២១ មួយចំនួន។

## II. សាវតារ

2. នៅថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០១៦ មេធាវីការពារក្ដីបានដាក់សំណើ អនុលោមតាមវិធាន ៩២ នៃវិធានផ្ទៃក្នុងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ស្នើសុំប្រើប្រាស់ចម្លើយសារភាព ស-២១ មួយចំនួន ដោយសំអាងថា មានភស្ដុតាងជំទាស់ទៅនឹងការសន្និដ្ឋានដែលថាមានហានិភ័យពិតប្រាកដដែលចម្លើយសារភាពជាក់លាក់ទាំងនេះ ទទួលបានដោយការធ្វើទារុណកម្ម ("សំណើ")[1]។

3. នៅថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១៦ សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ("សហមេធាវីនាំមុខ") និងសហព្រះរាជអាជ្ញា បានដាក់ចម្លើយតបរបស់ខ្លួន ("ចម្លើយតបរបស់សហមេធាវីនាំមុខ" និង"ចម្លើយតបរបស់សហព្រះរាជអាជ្ញា") ទៅនឹងសំណើនេះ[2]។ ចម្លើយតបរបស់សហមេធាវីនាំមុខត្រូវបានប្រកាសឲ្យដឹងនៅថ្ងៃដដែលនោះដែរ ដោយឡែកចម្លើយតបរបស់សហព្រះ រាជអាជ្ញាត្រូវបានប្រកាសឲ្យដឹង នៅថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ២០១៦។

4. នៅថ្ងៃទី ៤ ខែ ឧសភា ឆ្នាំ ២០១៦ មេធាវីការពារក្ដីបានស្នើសុំការអនុញ្ញាតពីអង្គជំនុំជម្រះសាលា

---

[1] ឯកសារ E399 "សំណើរបស់ នួន ជា អនុលោមតាមវិធាន ៩២ នៃវិធានផ្ទៃក្នុង សុំប្រើប្រាស់ចម្លើយសារភាព ស-២១ មួយចំនួន" ថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០១៦ ("សំណើ")។

[2] ឯកសារ E399/1 "ចម្លើយតបរបស់សហមេធាវីនាំមុខ ទៅនឹងសំណើរបស់ នួន ជា អនុលោមតាមវិធាន ៩២ នៃវិធានផ្ទៃក្នុង សុំប្រើប្រាស់ចម្លើយសារភាព ស-២១ មួយចំនួន" ថ្ងៃទី ០២ ខែ ឧសភាព ឆ្នាំ ២០១៦ ("ចម្លើយតបរបស់សហមេធាវីនាំមុខ")។ ឯកសារ E399/2 "ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើរបស់ នួន ជា អនុលោមតាមវិធាន ៩២ នៃវិធានផ្ទៃក្នុង សុំប្រើប្រាស់ចម្លើយសារភាព ស-២១ មួយចំនួន" ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៦ ("ចម្លើយតបរបស់សហព្រះរាជអាជ្ញា")។

ដំបូង ដាក់សារណាតបដាច់ដោយឡែកពីគ្នា ទៅនឹងចម្លើយតបរបស់សហមេធាវីនាំមុខ នៅថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០១៦ និងចម្លើយតបរបស់សហព្រះរាជអាជ្ញា នៅថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១៦ និងដាក់សារណាទាំងនេះតែជាភាសាអង់គ្លេសសិន ដោយដាក់សំណៅបកប្រែជាភាសាខ្មែរតាមក្រោយឱ្យបានឆាប់តាមដែលអាចធ្វើបាន”[3]។

5. នៅថ្ងៃទី ៥ ខែ ឧសភា ឆ្នាំ ២០១៦ អង្គជំនុំជម្រះសាលាដំបូងយល់ស្របតាមសំណើរបស់មេធាវីការពារក្តីមួយផ្នែក ដោយណែនាំឱ្យមេធាវីការពារក្តីដាក់សារណាតបរួម នៅថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០១៦ ជាភាសាអង់គ្លេស ដោយដាក់សំណៅបកប្រែជាភាសាខ្មែរតាមក្រោយ[4]។ បន្ទាប់ពីមានសេចក្តីសម្រេចបែបនេះ នៅថ្ងៃដដែលនោះដែរ មេធាវីការពារក្តីបានស្នើសុំការអនុញ្ញាតពីអង្គជំនុំជម្រះបន្ថែមចំនួនទំព័រពី ១៥ ទំព័រ ទៅដល់ ៣០ ទំព័រ[5]។ អង្គជំនុំជម្រះសាលាដំបូងយល់ស្របតាមសំណើនេះមួយផ្នែក ដោយអនុញ្ញាតឱ្យមេធាវីការពារក្តីដាក់សារណាតបក្នុងចំនួន ២០ ទំព័រ[6]។

## III. ច្បាប់ជាធរមាន

6. ទាក់ទិននឹងវិធានបដិសេធភស្តុតាង ដែលមានចែងនៅក្នុងមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តិមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោក (“អនុសញ្ញាប្រឆាំងទារុណកម្ម”)[7] អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋាថា ពុំមាន “បទដ្ឋានអន្តរជាតិដែលត្រូវបានទទួលស្គាល់ជាសកលណាមួយ ដែលអាចពង្រីកការបដិសេធភស្តុតាងដែលបានមកដោយការធ្វើទារុណកម្ម រហូតដល់ភស្តុតាងទាំងអស់ដែលបានមកដោយ

---

[3] អ៊ីមែលពីមន្ត្រីពិគ្រោះយោបល់ផ្នែកច្បាប់របស់មេធាវីការពារក្តី ផ្ញើជូនមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ៤ ខែ ឧសភា ឆ្នាំ ២០១៦ (**ឯកសារភ្ជាប់ ១**)។

[4] អ៊ីមែលពីមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង ផ្ញើជូនភាគី ថ្ងៃទី ៥ ខែ ឧសភា ឆ្នាំ ២០១៦ (**ឯកសារភ្ជាប់ ២**)។

[5] អ៊ីម៉ែលពីមន្ត្រីពិគ្រោះផ្នែកច្បាប់របស់មេធាវីការពារក្តី ផ្ញើជូនមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ៥ ខែ ឧសភា ឆ្នាំ ២០១៦ (**ឯកសារភ្ជាប់ ៣**)។

[6] អ៊ីមែលពីមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង ផ្ញើជូនភាគី ថ្ងៃទី ៥ ខែ ឧសភា ឆ្នាំ ២០១៦ (**ឯកសារភ្ជាប់ ៤**)។

[7] អនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តិមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោក សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ 39/46 ឯកសារអង្គការសហប្រជាជាតិលេខ A/39/51 ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៨៤ ចូលជាធរមាននៅថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៨៧។

អំពើឃោរឃៅ អមនុស្សធម៌ និងការបន្ទាបបន្ថោកនោះទេ"។ អង្គជំនុំជម្រះបានសន្និដ្ឋានទៀតថា អង្គជំនុំជម្រះ "យល់ឃើញថា មាត្រា ១៥ នៃអនុសញ្ញាប្រឆាំងទារុណកម្មមិនមានវិសាលភាពគ្របដណ្តប់ទៅលើភស្តុតាងដែលបានមកដោយការធ្វើបាប" "ដែលមិនមែនជាការធ្វើទារុណកម្ម" នោះទេ[8]។

7. ភាពខុសគ្នារវាងការធ្វើទារុណកម្ម និងការប្រព្រឹត្តិអមនុស្សធម៌ ឬបន្ទាបបន្ថោក៖

> អនុញ្ញាតឲ្យស្លាកស្នាមពិសេសនៃ "ការធ្វើទារុណកម្ម" ផ្សាភ្ជាប់តែទៅនឹងការប្រព្រឹត្តិអមនុស្សធម៌ ដោយចេតនាប៉ុណ្ណោះ ដែលបង្កឲ្យមានការឈឺចាប់យ៉ាងធ្ងន់ធ្ងរ និងអាក្រក់បំផុត [...]។ ក្រៅពីការប្រព្រឹត្តិដែលមានលក្ខណៈធ្ងន់ធ្ងរ មានធាតុផ្សំច្បាស់លាស់ជាក់លាក់មួយដែលកំណត់និយមន័យទារុណកម្ម ពាក់ព័ន្ធនឹងការបង្កឲ្យមានការឈឺចាប់ ឬរងទុក្ខយ៉ាងខ្លាំងដោយចេតនា ក្នុងគោលបំណង *ក្នុងចំណោមប្រការផ្សេងទៀត* ដើម្បីទទួលបានព័ត៌មាន ដាក់ទណ្ឌកម្ម ឬបំភិតបំភ័យ[9]។

8. សម្រាប់ផ្នែកដែលនៅសេសសល់នៃច្បាប់ជាធរមាន មេធាវីការពារក្តីផ្អែកទៅលើសំណើ (កថាខណ្ឌ ៨ ដល់ ១៤)។

## IV. សារណាតប

## ក. លក្ខខណ្ឌនៃការឃុំខ្លួន និងការបង្ខំផ្លូវចិត្តនៅមន្ទីរ ស-២១ ដែលបានចោទប្រកាន់នោះមិនមែនជាការធ្វើទារុណកម្មទេ

9. សហព្រះរាជអាជ្ញាជំទាស់ថា "សូម្បីតែមិនមាន" ការធ្វើទារុណកម្មលើរាងកាយដោយផ្ទាល់ទៅលើអ្នកជាប់ឃុំឃាំងនៅក្នុងអំឡុងពេលនៃការសួរចម្លើយក៏ដោយ ក៏ "លក្ខខណ្ឌនៃការឃុំខ្លួន" និង "ការបង្ខំផ្លូវចិត្តធ្ងន់ធ្ងរ" នៅក្នុងអំឡុងពេលនៃការសួរចម្លើយបង្ហាញថាមានហានិភ័យពិតប្រាកដ

---

[8] ឯកសារ **E350/8** "សេចក្តីសម្រេចលើភស្តុតាងដែលបានមកដោយការធ្វើទារុណកម្ម" ថ្ងៃទី ៥ ខែ កុម្ភៈ ឆ្នាំ ២០១៦ ("សេចក្តីសម្រេចរបស់ អ.ជ.ស.ជ") កថាខណ្ឌ ៦១ និងជើងទំព័រ ១២៦។

[9] សូមមើល ឧទា. រឿងក្តី *El-Masri* ទល់នឹង ម៉ាសេដូន តុលាការ ECtHR ពាក្យបណ្តឹងលេខ 39630/09 សាលក្រម ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១២ ("រឿងក្តី *El-Masri* case" ឯកសារភ្ជាប់ ៥) កថាខណ្ឌ ១៩៧។

ដែលថា "ចម្លើយសារភាពរបស់អ្នកដែលត្រូវបានសួរចម្លើយនៅមន្ទីរ ស-២១ ទទួលបានតាមរយៈការប្រើប្រាស់ទារុណកម្មផ្លូវចិត្ត និងផ្លូវកាយ"[10]។

10. ទោះបីជាយ៉ាងណាក៏ដោយ មេធាវីការពារក្តីអះអាងថា ដោយគ្មានអំពើហិង្សាលើរាងកាយធ្ងន់ធ្ងរ លក្ខខណ្ឌនៃការឃុំខ្លួននៅមន្ទីរ ស-២១ ឬការបង្ខំផ្លូវចិត្តតែមួយមុខ ឬក៏ចំណុចទាំងពីរបញ្ចូលគ្នានោះ មិនគ្រប់គ្រាន់ដើម្បីបង្កើតបានជាការធ្វើទារុណកម្ម ឬដើម្បីបញ្ជាក់ពីហានិភ័យពិតប្រាកដនៃការធ្វើទារុណកម្មឡើយ។

### *(i) លក្ខខណ្ឌនៃការឃុំខ្លួន*

11. តាំងពីដំបូង មេធាវីការពារក្តីកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០១ បានសម្រេចថា លក្ខខណ្ឌនៃការឃុំខ្លួនដែលបានចោទប្រកាន់ ដូចបានសង្ខេបជូនដោយសហព្រះរាជអាជ្ញានោះ[11] គឺជា "អំពើអមនុស្សធម៌ផ្សេងៗទៀត" មិនមែនជាការធ្វើទារុណកម្មទេ[12]។ ត្រូវចងចាំថា បញ្ហាអំពីថាតើលក្ខខណ្ឌនៃការឃុំខ្លួន អាចត្រូវបានបញ្ជាក់ ឬអត់ ហើយប្រសិនបើមានការបញ្ជាក់ថាតើលក្ខខណ្ឌទាំងនេះអាច ឬមិនអាចបង្កើតបានជាអំពើអមនុស្សធម៌ ឬយ៉ាងណានោះ នៅតែជាបញ្ហាចម្រូងចម្រាសនៅក្នុងសំណុំរឿង ០០២/០២ នោះ មេធាវីការពារក្តីអះអាងថា លក្ខខណ្ឌបែបនេះ អាចយ៉ាងច្រើនបំផុតជាការធ្វើបាបប៉ុណ្ណោះ មិនមែនជាការធ្វើទារុណកម្មនោះទេ។

12. ទាក់ទិននឹងលក្ខខណ្ឌនៃការឃុំខ្លួន សហព្រះរាជអាជ្ញាសង្កត់ធ្ងន់ទៅលើ "បរិយាកាសភ័យខ្លាច" ដែលបានចោទប្រកាន់ និងផ្តល់ទឡ្ហីករណ៍ថា "ការរស់នៅក្នុងស្ថានភាពភ័យខ្លាចជាប្រចាំ ដែលបង្កឡើងដោយការរំលោភបំពានផ្លូវកាយ និងការឃុំឃាំង បង្កើតបានជាទុក្ខវេទនាផ្លូវចិត្ត ដែល

---

[10] ឯកសារ E399/2 ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៤។

[11] ឯកសារ E399/2 ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៥-១៧ (មិនរាប់បញ្ចូលជើងទំព័រ ៣៩, ៦១, ៦២, ៦៤, ៦៦, ៦៧) ដែលដកស្រង់ ក្នុងចំណោមប្រការផ្សេងទៀត សំណុំរឿង ០០១ ឯកសារ E188 សាលក្រម សំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អ.វ.ត.ក/អ.ជ.ស.ជ ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ ("សាលក្រមសំណុំរឿង ០០១") កថាខណ្ឌ ២៥៨-៦០, ២៦២-៦៥, ២៦៨-៧០, ២៧២។

[12] សាលក្រមសំណុំរឿង ០០១ កថាខណ្ឌ ២៥៨-៧៨ និង ៣៧២-៧៣។

ក្លាយជាទារុណកម្ម”[13]។ នេះគឺជាការយល់ខុសលើអង្គច្បាប់។ នៅក្នុងរឿងក្ដី *Hajrulahu* ដែលសហព្រះរាជអាជ្ញាបានដកស្រង់ដើម្បីគាំទ្រទឡ្ហីករណ៍របស់ខ្លួននោះ តុលាការសិទ្ធិមនុស្សអឺរ៉ុប (“តុលាការ ECtHR”) មិនបានសន្និដ្ឋានថា ភាពភ័យខ្លាច ភាពថប់អារម្មណ៍ ភាពតានតឹងក្នុងចិត្ត និងទុក្ខវេទនាផ្លូវចិត្ត មានលក្ខណៈគ្រប់គ្រាន់ដើម្បីបង្កើតបានជាទារុណកម្មនោះឡើយ។ ប៉ុន្តែសេចក្ដីសន្និដ្ឋានអំពីទារុណកម្មនៅក្នុងរឿងក្ដីនោះ ផ្អែកទៅលើ “ការរួមបញ្ចូលគ្នា” នៃវិធានការទាំងអស់ដែលបានប្រើប្រាស់ រួមទាំងហិង្សាលើផ្លូវកាយធ្ងន់ធ្ងរ ដូចជា ការវាយដំដែលបង្កឱ្យមានស្នាមជាំពេញនៅលើរាងកាយរបស់អ្នកដាក់ពាក្យបណ្ដឹង ការចាប់អ្នកដាក់ពាក្យបណ្ដឹងជ្រមុជចូលទៅក្នុងទឹក ដោយដៃ និងជើងរបស់គាត់ជាប់ខ្នោះ និងការយកឆ្កែមកគំរាមអ្នកដាក់ពាក្យបណ្ដឹង[14]។ ផ្ទុយទៅវិញ នៅក្នុងរឿងក្ដី *El-Masri* ដែលពុំមានការប្រើប្រាស់ “កម្លាំងកាយ” នោះ លក្ខខណ្ឌស្រដៀងគ្នាដែលបង្កឱ្យអ្នកដាក់ពាក្យបណ្ដឹងមានភាពភ័យខ្លាច ភាពថប់អារម្មណ៍ ភាពតានតឹងក្នុងចិត្ត និងទុក្ខវេទនាផ្លូវចិត្ត ត្រូវបានតុលាការ ECtHR សន្និដ្ឋានថាជាការប្រព្រឹត្តិអមនុស្សធម៌ និងបន្ថាបបន្ថោក មិនមែនទារុណកម្មទេ[15]។ តាមពិត តុលាការ ECtHR បានសន្និដ្ឋានថា

---

[13] ឯកសារ **E399/2** ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៥, ១៧ និងកថាខណ្ឌ ១២ ដែលដកស្រង់សំណុំរឿង *Hajrulahu* ទល់នឹង ម៉ាសេដ្វាន តុលាការ ECtHR ពាក្យបណ្ដឹងលេខ 37537/07 សាលក្រម ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៦ (“រឿងក្ដី *Hajrulahu* ” ឯកសារភ្ជាប់ ៦)។

[14] រឿងក្ដី *Hajrulahu* កថាខណ្ឌ ១០០-១០១។

[15] រឿងក្ដី *El-Masri* កថាខណ្ឌ ២០០, ២០២-២០៤។ “ទាក់ទិននឹងការប្រព្រឹត្តិចំពោះអ្នកដាក់ពាក្យបណ្ដឹងនៅឯសណ្ឋាគារ តុលាការកត់សម្គាល់ឃើញថា គាត់ស្ថិតក្រោមការឃាមកាមជាប្រចាំពីសំណាក់ភ្នាក់ងារសន្តិសុខម៉ាសេដ្វាន ត្រូវបានគេសួរចម្លើយជាភាសាបរទេសដែលគាត់មានការយល់ដឹងតិចតួច ត្រូវបានគេគំរាមដោយប្រើកាំភ្លើង និងជានិច្ចកាលមិនត្រូវបានគេអនុញ្ញាតឱ្យជួបនរណាម្នាក់ឡើយ ក្រៅតែពីអ្នកសួរចម្លើយគាត់។ ដោយសារតែការប្រព្រឹត្តិបែបនេះហើយ ទើបអ្នកដាក់ពាក្យបណ្ដឹងធ្វើការតវ៉ាប្រឆាំង តាមរយៈការធ្វើកូដកម្មអត់អាហាររយៈពេលដប់ថ្ងៃ។ [...] ជាការពិតហើយ ខណៈដែលគាត់ត្រូវបានឃុំខ្លួននៅឯសណ្ឋាគារនោះ ពុំមានការប្រើប្រាស់កម្លាំងកាយទៅលើអ្នកដាក់ពាក្យបណ្ដឹងនោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ តុលាការអះអាងបញ្ជាក់ឡើងវិញថា មាត្រា ៣ មិនសំដៅទាំងស្រុងតែទៅលើការបង្កឱ្យមានការឈឺចាប់ផ្លូវកាយប៉ុណ្ណោះទេ ប៉ុន្តែការបង្កឱ្យមានទុក្ខវេទនាផ្លូវចិត្តផងដែរ ដែលកើតឡើងដោយសារការបង្កើតឱ្យមានស្ថានភាពតានតឹងក្នុងចិត្ត និងសម្ពាធផ្លូវចិត្ត តាមវិធីផ្សេងៗក្រៅពីការវាយដំលើរាងកាយ។ វាប្រាកដណាស់ដែលថា ការឃុំខ្លួនអ្នកដាក់ពាក្យបណ្ដឹងឱ្យនៅតែម្នាក់ឯងនៅឯសណ្ឋាគារនោះ បានធ្វើឱ្យរូបគាត់ភិតភ័យ ដោយសារតែគាត់មានក្ដីបារម្ភ ថាតើនឹងមានអ្វីកើតឡើងចំពោះរូបគាត់បន្ទាប់មកទៀត និងប្រាកដជាបានធ្វើឱ្យគាត់ឈឺចាប់ផ្លូវអារម្មណ៍ និងផ្លូវចិត្ត។ ការឃុំឃាំងអ្នកដាក់ពាក្យបណ្ដឹងរយៈពេលយូរនៅឯសណ្ឋាគារ បានធ្វើឱ្យគាត់ចុះទន់ខ្សោយយ៉ាងខ្លាំង។ គាត់ពិតជាបានរស់នៅក្នុងស្ថានភាពថប់អារម្មណ៍ជាប្រចាំ ដោយសារ

ការប្រព្រឹត្ដិ ដែល "នាំឲ្យជនរងគ្រោះមានអារម្មណ៍ភ័យខ្លាច តានតឹងក្នុងចិត្ត និងអន់ជាងអ្នកដទៃ ដែលអាចធ្វើឲ្យពួកគេអាម៉ាស់ និងអាប់អោន និងអាចកាច់បំបាក់នូវភាពជម្នះខាងផ្លូវកាយ ឬ ផ្លូវចិត្តរបស់ពួកគេនោះ" ជាធម្មតាគឺជាការប្រព្រឹត្តិបន្ទាបបន្ថោក[16] ដែលខុសគ្នាពីការធ្វើទារុណកម្ម។

13. ជាងនេះទៀត ស្ថានភាពខ្លះក្នុងចំណោមស្ថានភាពនានាដែលបានលើកឡើងដោយសហព្រះរាជអាជ្ញា ដូចជាអ្នកជាប់ឃុំត្រូវបានឃុំឃាំងដោយមានអ្នកយាមបំពាក់អាវុធនោះ ត្រូវបានដាក់ខ្នោះ នៅពេលផ្លាស់ប្តូរទីកន្លែង និងត្រូវបានឃុំនៅក្នុងបន្ទប់ធំដែលមានបង្អួចចំរឹងដែក[17] ពុំមែនមានន័យថាជា "ទុក្ខព្រួយ ឬ ការលំបាកកាន់តែកើនឡើងដល់កម្រិតឈឺចាប់ដែលមិនអាចចៀសវាងបានដោយសារការឃុំឃាំង" និង "តម្រូវការជាក់ស្តែងនៃការជាប់ឃុំឃាំង"[18]។ ហេតុនេះ ស្ថានភាពទាំងនេះមិនគ្រប់គ្រាន់ ដើម្បីបង្កើតជាការប្រព្រឹត្តិបែបអមនុស្សធម៌ ឬការបន្ទាបបន្ថោកនោះទេ[19]។

14. ស្ថានភាពដែលគួរឲ្យរន្ធត់បំផុតដែលសហព្រះរាជអាជ្ញាបានចោទប្រកាន់គឺថា អ្នកជាប់ឃុំត្រូវបានបង្ខំឲ្យលិឍទឹកនោម និងឈាមដែលហៀរក្នុងបន្ទប់ ត្រូវបានផ្អែកទៅលើសក្ខីកម្មនាពេលថ្មីៗរបស់

---

តែភាពមិនប្រាកដប្រជារបស់គាត់អំពីជោគវាសនារបស់គាត់ នៅក្នុងអំឡុងពេលដែលគាត់ត្រូវស្ថិតនៅក្រោមការសួរចម្លើយនោះ។ តុលាការកត់សម្គាល់ថា អ្នកដាក់ពាក្យបណ្តឹងបានទទួលរងនូវការប្រព្រឹត្តិបែបនេះដោយចេតនា ក្នុងគោលបំណងដើម្បីទាញយកចម្លើយសារភាព ឬព័ត៌មានអំពីចំណងទាក់ទងរបស់គាត់ជាមួយនឹងអង្គការភេរវកម្ម ដែលត្រូវបានគេចោទប្រកាន់នោះ។ លើសពីនេះទៀត ការគំរាមដែលថាគាត់នឹងត្រូវគេបាញ់សម្លាប់ ប្រសិនបើគាត់ចាកចេញពីបន្ទប់សណ្ឋាគារនោះ គឺមានលក្ខណៈពិតប្រាកដ និងដោយផ្ទាល់យ៉ាងគ្រប់គ្រាន់។ [...] ចុងក្រោយ ភាពរងទុក្ខរបស់អ្នកដាក់ពាក្យបណ្តឹង កាន់តែកើនឡើងថែមទៀត តាមរយៈដំណើរការដែលមានលក្ខណៈសម្ងាត់ និងអង្គហេតុដែលគាត់ត្រូវបានគេឃុំខ្លួនដោយមិនអនុញ្ញាតឲ្យមានការប្រាស្រ័យទាក់ទងគ្នារយៈពេល ២៣ថ្ងៃ នៅក្នុងសណ្ឋាគារមួយ ដែលជាកន្លែងឃុំខ្លួនពិសេស នៅក្រៅក្របខណ្ឌតុលាការ។ [...] ដោយពិចារណាទៅលើហេតុផលខាងលើ តុលាការយល់ឃើញថា ការប្រព្រឹត្តទៅលើអ្នកដាក់ពាក្យបណ្តឹងនៅឯសណ្ឋាគារនោះ តាមបទចោទផ្សេងៗ គឺជាការប្រព្រឹត្តអមនុស្សធម៌ និងបន្ទាបបន្ថោក"។

[16] *សូមមើល* ខទា. រឿងក្តី *Hajrulahu* កថាខណ្ឌ ៩៧។

[17] ឯកសារ **E399/2** ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៦។

[18] *រឿងក្តី Gelfmann តទល់នឹង ប្រទេសបារាំង* តុលាការ ECtHR ពាក្យសុំលេខ 25875/03 សាលក្រម ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៤ (**ឯកសារបន្ថែម ៧**) កថាខណ្ឌ ៥០។

[19] ដូចយោងខាងលើ។

ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី តែម្នាក់គត់ ដែលបានផ្ដល់សក្ខីកម្មនៅក្នុងសំណុំរឿង ០០១ តែហាក់ដូចជាបានលុបចោលនូវព័ត៌មានលម្អិតនាពេលនោះវិញ[20]។ ដូចបានពន្យល់ខាងលើ មេធាវីការពារក្ដីលើកឡើងថា ទោះបីមានភ័ស្តុតាងបញ្ជាក់ក៏ដោយ ក៏យ៉ាងច្រើនណាស់ ស្ថានភាពនេះត្រឹមតែជាការធ្វើបាប ពុំមែនជាការធ្វើទារុណកម្មទេ។ ជាងនេះទៀត ពុំមានភ័ស្តុតាងទាល់តែសោះដែលបង្ហាញថា ការបំពារបំពានទាំងនេះត្រូវបានយកមកប្រើប្រាស់ ក្នុងគោលបំណងទទួលបានចម្លើយពីអ្នកជាប់ឃុំទាំងនោះ[21]។ អំណះអំណាងរបស់សហព្រះរាជអាជ្ញាដែលថា "[លក្ខខណ្ឌនៃការឃុំឃាំងនៅ ស-២១ ...] បានធ្វើឲ្យអ្នកទោសចុះខ្សោយ*សម្រាប់ត្រៀមការសួរចម្លើយ*"[22] ពុំមានមូលដ្ឋានទេ។ ជាងនេះទៀត សហព្រះរាជអាជ្ញាពុំបានយោងទៅដល់ភ័ស្តុតាងណាមួយដើម្បីគាំទ្រដល់ធាតុផ្សំដែលបានលើកឡើងនោះទេ[23]។ ក្រៅពីនេះ មេធាវីការពារក្ដីកត់សម្គាល់ថា "ចម្លើយដែលបានផ្ដល់ពី [...] អ្នកដែលអះអាងថាជាជនរងគ្រោះនៅក្នុងរឿងក្ដីនេះ ដែលអាចមានផលប្រយោជន៍ដោយផ្ទាល់" ត្រូវតែយកមកពិនិត្យដោយប្រុងប្រយ័ត្ន និង "គួរតែត្រូវបានយកមកវាយតម្លៃនៅក្នុងបរិបទនៃភ័ស្តុតាងជារួម"[24]។ ទាក់ទិននឹងចំណុចនេះ ក្រៅពីពុំមានភ័ស្តុតាងបញ្ជាក់ការចោទប្រកាន់របស់ ជុំ ម៉ី ហាក់ដូចជាគួរឲ្យមានការសង្ស័យជាខ្លាំង ដោយសារថា ភ័ស្តុតាងមួយក្នុងចំណោមភ័ស្តុតាងជាឯកសារបន្សល់ទុកពីសម័យខ្មែរក្រហមដែលមានចំពោះមុខអង្គជំនុំជម្រះសាលាដំបូងបង្ហាញថា អ្នកយាមនៅ ស-២១ ត្រូវបានណែនាំ "ដាច់ខាត" មិនឲ្យ "សម្លុត ឬវាយធ្វើបាបអ្នកទោស" និងត្រឹមតែរាយការណ៍ "បើខ្មាំងសេរី អ្នកយាមនិយាយ

---

[20] ឯកសារ **E399/2** ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៦ ជើងទំព័រ ៥១។ ទោះបីជើងទំព័រ ៥១ ក៏យោងទៅដល់កថាខណ្ឌ ២៧២ នៃសាលក្រមជំនុំជម្រះក្នុងសំណុំរឿង ០០១ ក៏ដោយ តែកថាខណ្ឌដែលបានយោង ត្រឹមតែសន្និដ្ឋានថាអ្នកជាប់ឃុំត្រូវតែបន្ទោរបង់នៅក្នុងបន្ទប់ឃុំឃាំង។

[21] មាត្រា ១៥ នៃអនុសញ្ញាប្រឆាំងទារុណកម្ម ត្រឹមតែអនុវត្តចំពោះចម្លើយតែទទួលបានតាមរយៈការធ្វើទារុណកម្មប៉ុណ្ណោះ។

[22] ឯកសារ **E399/2** ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៦ (គូសបញ្ជាក់បន្ថែម)។

[23] *សូមមើល ខាងលើ* កថាខណ្ឌ ៧។

[24] *សំណុំរឿង Loayza-Tamayo តទល់នឹង ប្រទេសប៉េរូ* តុលាការ IACtHR, Series C No. 33, សាលក្រម ចុះថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ ១៩៩៧ (**ឯកសារបន្ថែម ៨**) កថាខណ្ឌ ៤៣។ មេធាវីការពារក្ដីលើកឡើងថា ការប្រុងប្រយ័ត្នបែបនេះត្រូវតែអនុវត្តចំពោះភ័ស្តុតាងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ រួមមាន ជុំ ម៉ី, វ៉ាន់ ណាត និង ប៊ូ ម៉េង ដែលភ័ស្តុតាងរបស់ពួកគេត្រូវបានសហព្រះរាជអាជ្ញាយកមកសំអាងដោយផ្ទាល់ផង និងដោយប្រយោលផង នៅក្នុងចម្លើយតបរបស់ខ្លួន។

មិនស្តាប់”[25]។

15. ជាងនេះទៀត ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី, វ៉ាន់ ណាត និង ប៊ូ ម៉េង ដែលភ័ស្តុតាងរបស់ពួកគាត់ត្រូវបានសហព្រះរាជអាជ្ញាយកមកសំអាងជាច្រើន ដើម្បីបង្ហាញពីស្ថានភាពនៅ ស-២១ នោះ ត្រូវបានឃុំឃាំងនៅ ស-២១ ត្រឹមតែចាប់ពីឆ្នាំ ១៩៧៨ រហូតដល់ចុងរបបនេះប៉ុណ្ណោះ។ ស្ថានភាពឃុំឃាំងដែលពួកគាត់អះអាងថាបានទទួលរង ពុំពាក់ព័ន្ធនឹងការសម្រេចពីស្ថានភាពនៃការឃុំឃាំងនៅឆ្នាំ ១៩៧៦ និងឆ្នាំ ១៩៧៧ ដែលពាក់ព័ន្ធនឹងពេលឃុំឃាំង កុយ ធួន, យឹម សម្បត្តិ និង ជា ណុនទេ។

16. ជាងនេះទៀត មេធាវីការពារក្តីកត់សម្គាល់ថា ក្នុងការសម្រេចថាតើការប្រព្រឹត្តិមួយចំនួនអាចដល់កម្រិតអប្បបរមានៃភាពធ្ងន់ធ្ងរដើម្បីបង្កើតជាការធ្វើទារុណកម្ម ឬ ការប្រព្រឹត្តិបែបអមនុស្សធម៌ និងការបន្ទាបបន្ថោកនោះ កាលៈទេសៈទាំងអស់ត្រូវតែយកមកពិចារណា រួមទាំង*ស្ថានភាពទូទៅ*ដែលអ្នកអះអាងថាជាជនរងគ្រោះបានស្ថិតនៅ។ ឧទាហរណ៍ ទោះបីកង្វះខាតមុង[26] អាចត្រូវបានចាត់ទុកជាអំពើអមនុស្សធម៌ ឬជាការបន្ទាបបន្ថោកសម្រាប់ជនជាតិអឺរ៉ុប រស់នៅក្នុងឆ្នាំ ២០១៦ ក្តីក៏វាដូចជាពុំបានបង្ហាញពីអារម្មណ៍អវិជ្ជមានស្រដៀងគ្នានេះទេសម្រាប់ប្រជាជនកម្ពុជាដែលរស់នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៧០។ ឌុច ធ្លាប់បាននិយាយថា “នៅពេលនោះ នៅស-២១ ខ្ញុំជម្រាបដោយស្មោះត្រង់ចុះ ផ្ទាល់ខ្លួនខ្ញុំ ក៏ខ្ញុំមិនដែលដេកដាក់មុងដែរ”[27]។ ដោយសារមានស្ថានភាពទូទៅបែបនេះ ការពុំមានមុងមិនអាចត្រូវបានចាត់ទុកថាជាការប្រព្រឹត្តិមិនត្រឹមត្រូវដល់អ្នកជាប់ឃុំនៅ ស-២១ ហើយក៏មិនដល់កម្រិតអប្បបរមានៃភាពធ្ងន់ធ្ងរដើម្បីកំណត់ថាជាការធ្វើទារុណកម្ម ឬ ការប្រព្រឹត្តិបែបអមនុស្សធម៌ ឬការបន្ទាបបន្ថោកដែរ។

17. មេធាវីការពារក្តីក៏កត់សម្គាល់ផងដែរថា សហព្រះរាជអាជ្ញាបានដកស្រង់យុត្តិសាស្ត្ររបស់តុលាការ ICTR ដើម្បីលើកជាទឡ្ហីករណ៍ថា “បុគ្គលអាចទទួលរងព្យសនកម្មផ្លូវចិត្តធ្ងន់ធ្ងរ តាមរយៈការ

---

[25] ឯកសារ **E3/8386** សារាចរនៅ ស-២១, EN 00521631។

[26] ឯកសារ **D427** “ដីកាដំណោះស្រាយ” ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ កថាខណ្ឌ ៤៤៣។

[27] ប្រតិចារឹកសវនាការថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៩ (កាំង ហ្កេកអ៊ាវ *ហៅ* ឌុច ឯកសារ **E3/5799**) ទំព័រ ៣៦ បន្ទាត់ ៧-១១។

ឃើញអំពើដែលបានប្រព្រឹត្តប្រឆាំងនឹងបុគ្គលផ្សេងទៀត”[28] តែការធ្វើរបៀបនេះ ដោយពុំបានយោងទៅដល់ភស្តុតាងណាមួយដើម្បីបង្ហាញថា អ្នកជាប់ឃុំនៅ ស-២១ ត្រូវបានធ្វើឱ្យឃើញផ្ទាល់ភ្នែកនូវអំពើហិង្សាប្រឆាំងនឹងអ្នកផ្សេងទេ។ ក្នុងករណីនេះ មេធាវីការពារក្តីចង់លើកឡើងថា ដំបូង នៅពេលធ្វើការសន្និដ្ឋាននៅក្នុងរឿងក្តី *Kayishema និងអ្នកផ្សេងទៀត* ដែលពួកគេបានដកស្រង់ អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR បានយោងដល់ “អំពើអមនុស្សធម៌ផ្សេងៗទៀត” ពុំមែនការធ្វើទារុណកម្មទេ[29]។ ទីពីរ មេធាវីការពារក្តីសើកឡើងថា ការឮសំឡេងស្រែក ឬឃើញស្នាមរបួសលើខ្លួនដទៃ[30] មិនស្របទៅនឹងអ្វីដែលអង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR បានពិពណ៌នាថាជា “ការបានឃើញអំពើនានាដែលត្រូវបានប្រព្រឹត្តទៅលើអ្នកផ្សេងទៀត” ទេ[31]។ នៅក្នុងករណីណាក៏ដោយ ប្រសិនបើឃើញគ្រួសារត្រូវបានសម្លាប់យ៉ាងសាហាវព្រៃផ្សៃ ទង្វើនោះត្រូវបានតុលាការ ICTR ចាត់ទុកត្រឹមជាអំពើអមនុស្សធម៌ប៉ុណ្ណោះ វានឹងការហួសហេតុពេកដែលលើកជាទឡ្ហីករណ៍ថា ការណ៍ដែលអ្នកជាប់ឃុំ បានឮសំឡេងស្រែក និងបានឃើញស្នាមរបួសលើខ្លួនអ្នកផ្សេង ដែលហាក់ដូចជាមនុស្សមិនធ្លាប់ស្គាល់គ្នា ត្រូវបានចាត់ទុកថាជាការធ្វើទារុណកម្មនោះ។

## *(ii)* ***ការបង្ខិតបង្ខំផ្លូវចិត្ត***

18. សហព្រះរាជអាជ្ញាជំទាស់តវ៉ាថា ការបង្ខិតខង្ខំផ្លូវចិត្ត ដូចជា ការគំរាមកំហែងប្រើប្រាស់ការធ្វើទារុណកម្ម ទោះដោយការបង្ហាញឧបករណ៍ធ្វើទារុណកម្មក្តី ឬដោយការគំរាមកំហែងជាក់លាក់ណាមួយក្តី ក៏ដូចជា ការគំរាមកំហែងទៅលើក្រុមគ្រួសាររបស់អ្នកជាប់ឃុំឃាំងផងដែរ គឺស្មើនឹង

---

[28] ឯកសារ **E399/2** ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១២ ជើងទំព័រ ៣៣ ដកស្រង់ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kayishema និងអ្នកផ្សេងទៀត* សំណុំរឿងលេខ សាលក្រម ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៩៩ (“រឿងក្តី *Kayishema និងអ្នកផ្សេងទៀត*” **ឯកសារបន្ថែម ៩**) កថាខណ្ឌ ១៥៣។

[29] រឿងក្តី *Kayishema និងអ្នកផ្សេងទៀត* កថាខណ្ឌ ១៥៣ ដែលស្ថិតក្នុងផ្នែកមានចំណងជើងថា “អំពើអមនុស្សផ្សេងៗទៀត” ដែលផ្តោតលើកថាខណ្ឌ ១៤៨-១៥៤។

[30] ឯកសារ **E399/2**, ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៧។

[31] រឿងក្តី *Kayishema និងអ្នកផ្សេងទៀត* កថាខណ្ឌ ១៥៣។

ការធ្វើទារុណកម្មផ្លូវចិត្តហើយ ទោះជាមិនមានការធ្វើទារុណកម្មលើរូបរាងការដោយផ្ទាល់ក្តី[32]។

19. ពិតហើយ តុលាការសិទ្ធិមនុស្សអន្តរអាមេរិក (“IACtHR”) បានសម្រេចថា “*នៅក្នុងកាលៈទេសៈជាក់លាក់មួយចំនួន* ការគំរាមកំហែង និងគ្រោះថ្នាក់ពិតប្រាកដនៃការឈឺចាប់ផ្លូវកាយ គឺស្ថិតក្នុងកម្រិតមួយនៃការឈឺចាប់ផ្លូវចិត្ត ដែល*អាច*ត្រូវបានយកមកពិចារណាថាជាទារុណកម្មផ្លូវចិត្ត”[33]។ ប៉ុន្តែ តាមរយៈការសម្រេចសេចក្តីនេះ វាច្បាស់ហើយថា ទោះបីជាការគំរាមកំហែង ឬគ្រោះថ្នាក់ពីការធ្វើទារុណកម្ម អាចនាំឲ្យក្លាយជាអំពើទារុណកម្មក្តី គឺអាស្រ័យទាំងស្រុងទៅលើកាលៈទេសៈទាំងនោះ។ យោងតាមតុលាការសិទ្ធិមនុស្សអន្តរអាមេរិក កាលៈទេសៈពាក់ព័ន្ធរួមមាន “អំឡុងពេលនៃការធ្វើបាប ការប៉ះពាល់ខាងផ្លូវកាយ ឬផ្លូវចិត្ត ហើយក្នុងករណីខ្លះ គឺមានកត្តាភេទ អាយុ និងស្ថានភាពសុខភាពរបស់ជនរងគ្រោះ”[34]។

20. ការបង្ហាញឧបករណ៍ធ្វើទារុណកម្ម កម្រឈានដល់កម្រិតអប្បបរមានៃភាពធ្ងន់ធ្ងរ ដើម្បីកំណត់ បានជាទារុណកម្មផ្លូវចិត្តណាស់។ ជាពិសេស ចំណុចនេះគឺស្ថិតនៅក្នុងករណីសព្វថ្ងៃ ដោយសារថាមនុស្សបីនាក់ដែលចោទជាបញ្ហារួមមាន កុយ ធួន, យឹម សម្បត្តិ និង ជា ណុន គឺជាបុរសពេញវ័យដែលអាចជាយុទ្ធជនប្រយុទ្ធស្រួចស្រាវ ឬ(ជាអតីត) មេបញ្ជាការយោធាជាន់ខ្ពស់។ លើសពីនេះទៅទៀត មិនមានភស្តុតាងគាំទ្រដល់អត្ថិភាពនៃការប្រើប្រាស់ជាប្រព័ន្ធ ក្នុងការបង្ហាញឧបករណ៍ធ្វើទារុណកម្ម ដើម្បីជាមធ្យោបាយគំរាមកំហែងអ្នកជាប់ឃុំឃាំងនៅ ស-២១ នោះទេ។ នៅក្នុងចម្លើយនាពេលថ្មីៗនេះ ឌុច បានបដិសេធប្រភេទភស្តុតាងរបស់ ប្រាក់ ខន ដែលទាក់ទងទៅនឹងការបង្ហាញឧបករណ៍ធ្វើទារុណកម្ម និងបានសង្ស័យថា ប្រហែលជា “ឧបករណ៍ទាំងនោះ ត្រូវបានគេយកមកដាក់នៅក្រោយថ្ងៃ ៧ មករា [១៩៧៩]”ទេ[35]។ ប្រាក់ ខន ខ្លួនឯងបានបញ្ជាក់ឲ្យដឹងនាពេលថ្មីៗនេះថា ពេលខ្លះគាត់គ្រាន់តែកាច់មែកឈើតូចមួយទំហំប៉ុនបិច ពីដើមឈើនៅក្បែរនោះ

---

[32] ឯកសារ **E399/2** ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៨។

[33] *រឿងក្តីរបស់ Baldeon-Garcia ទល់នឹង ប្រទេសប៉េរូ*, IACtHR, ស៊េរី C លេខ ១៤៧, សាលក្រម ចុះថ្ងៃទី ៦ ខែ មេសា ឆ្នាំ ២០០៦ (**ឧបសម្ព័ន្ធលេខ ១០**) កថាខណ្ឌ ១១៩ (មានការបញ្ជាក់សេចក្តីបន្ថែម)។

[34] *សូមមើល ឧ.ទា រឿងក្តីរបស់ El-Masri*, កថាខណ្ឌ ១៩៦។

[35] ឯកសារ **E319/42.3.1** “កំណត់ហេតុនៃការស្តាប់ចម្លើយ កាំង ហ្គេកអ៊ាវ *ហៅ* ឌុច” ចុះថ្ងៃទី ១ ខែ កុម្ភៈ ឆ្នាំ ២០១៦ (“កំណត់ហេតុស្តាប់ចម្លើយ ឌុច”), EN 01213414, A29។

ដើម្បីវាយអ្នកជាប់ឃុំឃាំង[36] ដែលនេះហាក់មិនស៊ីចង្វាក់គ្នាទៅនឹងការចោទប្រកាន់ថាមានការបង្ហាញដោយចេតនានូវឧបករណ៍ធ្វើទារុណកម្ម ដើម្បីជាការកំហែង ឬជាមធ្យោបាយមួយគំរាមកំហែងអ្នកជាប់ឃុំឃាំងនោះទេ។

21. ទាក់ទងនឹងការគំរាមកំហែងយ៉ាងច្បាស់លាស់ ដូចដែលបានចោទប្រកាន់ ចំពោះការប្រើប្រាស់ឯកសារដែលបានមកដោយការធ្វើទារុណកម្ម ដែលធ្វើឡើងដោយអ្នកសួរចម្លើយនៅ ស-២១ នោះពុំមានភស្តុតាងគាំទ្រដល់អត្ថិភាពនៃការប្រើប្រាស់ជាប្រព័ន្ធនៃការគំរាមកំហែង*ធ្ងន់ធ្ងរ* ដែលអាចអាចឈានដល់កម្រិតនៃការធ្វើទារុណកម្មផ្លូវចិត្តនោះទេ។ ដោយពិចារណាថាតើការគំរាមកំហែងបែបនោះអាចបណ្តាលឲ្យមានការធ្វើទារុណកម្មដែរ ឬអត់នោះ គឺវាអាស្រ័យទាំងស្រុងទៅលើកម្រិត និងកាលៈទេសៈនៃការគំរាមកំហែង[37] កង្វះភស្តុតាងស្តីពីភាពធ្ងន់ធ្ងរនៃការគំរាមកំហែងមានន័យថា មានលទ្ធភាពក្នុងការធ្វើទារុណកម្មផ្លូវចិត្តតែប៉ុណ្ណោះ ហើយលទ្ធភាពនេះពុំគ្រប់គ្រាន់ដើម្បីយកមកពិចារណាថាមាន "ហានិភ័យពិតប្រាកដ" បានទេ។

22. ទាក់ទងនឹងការគំរាមកំហែងទៅលើក្រុមគ្រួសារអ្នកជាប់ឃុំឃាំងវិញ មេធាវីការពារក្តីកត់សម្គាល់ឃើញតាំងពីដំបូងឡើយ ថាតើការគំរាមកំហែងតែមួយមុខថានឹងធ្វើទារុណកម្ម ឬសម្លាប់ក្រុមគ្រួសាររបស់អ្នកណាម្នាក់នោះ អាចចាត់ថាជាការធ្វើទារុណកម្មផ្លូវចិត្តនោះ នៅតែជាចំណោទបញ្ហានៅឡើយ។ យុត្តិសាស្ត្រដូចបានលើកឡើងខាងលើរបស់តុលាការសិទ្ធិមនុស្សអន្តរអាមេរិកហាក់ដូចជាមិនបានពន្លាតដល់ការគំរាមកហែង ឬគ្រោះថ្នាក់ពីការធ្វើទារុណកម្មនោះទេ រួមទាំងការគំរាមកហែង ឬគ្រោះថ្នាក់ពីការធ្វើទារុណកម្មទៅលើក្រុមគ្រួសាររបស់អ្នកណាម្នាក់ផងដែរ[38]។ លើសពីនេះទៅទៀត នៅក្នុងរឿងក្តីរបស់ *Maritza* ដែលអយ្យការបានចោទប្រកាន់នោះ តុលាការសិទ្ធិមនុស្សអន្តរអាមេរិកយល់ឃើញថា ទារុណកម្មផ្លូវចិត្តមិនមែនពឹងផ្អែកតែទៅលើការគំរាមកំហែងមកលើក្រុមគ្រួសារប៉ុណ្ណោះទេ។ ផ្ទុយទៅវិញ វាអាស្រ័យទៅលើការរួមបញ្ចូលគ្នានៃការគំរាមកំហែងទៅលើអាយុជីវិតនៃសមាជិកគ្រួសាររបស់ *Maritza* និងកត្តាដទៃទៀត ដូចជា ការ

[36] ប្រតិចារឹកសវនាការ ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៦ (សាក្សី ប្រាក់ ខន, សេចក្តីព្រាងប្រតិចារឹក) ទំព័រ ៦៦ បន្ទាត់ ១៥-១៦។ ប្រតិចារឹកសវនាការ ថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១៦ (សាក្សី ប្រាក់ ខន, សេចក្តីព្រាងប្រតិចារឹក) ទំព័រ ២៣ បន្ទាត់ ៩-១០។

[37] *សូមមើល* កថាខណ្ឌ ១៩ ខាងលើ។

[38] *សូមមើល* កថាខណ្ឌ ១៩ ខាងលើ លេខយោងជើងទំព័រ ៣៣ ដែលបង្កុលបង្ហាញពីរឿងក្តីរបស់ *Baldeon-Garcia* ។

ដកហូតដំណេក ការប្រឈមទៅនឹងសំឡេងរំខាន ឬពន្លឺភ្លឺជាប្រចាំ ការដកហូតសេរីភាពខាងផ្លូវអារម្មណ៍ដោយការគ្របមុខជារហូត ការគំរាមកំហែងជាបន្តបន្ទាប់ថានឹងត្រូវធ្វើទារុណកម្ម ឬរំលោភសេពសន្ថវៈ ។ល។[39]។

23. ទោះជាក្នុងករណីណាក៏ដោយ ការគំរាមកំហែងទៅលើសមាជិកគ្រួសាររបស់អ្នកជាប់ឃុំឃាំង ដូចជាការប្រាប់ទៅអ្នកជាប់ឃុំឃាំងថា ក្រុមគ្រួសាររបស់ពួកគេត្រូវបានឃុំឃាំងខ្លួន ឬប្រាប់ឱ្យអ្នកជាប់ឃុំឃាំងគិតអំពីក្រុមគ្រួសាររបស់ពួកគេ[40] មានន័យថា មិនទាន់ឈានដល់កម្រិតអប្បរមានៃភាពធ្ងន់ធ្ងរ ដែលនាំឱ្យគេយកកត្តាទាំងនោះមកពិចារណាថា ជាទារុណកម្មផ្លូវចិត្តនោះទេ។ លើសពីនេះទៀត មានភស្តុតាងបង្ហាញថា អ្នកជាប់ឃុំឃាំងនៅ ស-២១ ត្រូវបានគេប្រាប់ថា ពេលណាពួកគេសារភាព នោះពួកគេអាចទៅរស់នៅជួបជុំជាមួយប្រពន្ធ និងកូនរបស់ពួកគេវិញ ដែលកំពុងរង់ចាំពួកគេនៅឯផ្ទះ[41]។ ទោះបីវាគ្រាន់តែជាការភូតកុហក់ ឬមិនមែនជាការភូតកុហក់ក៏ដោយ ដូចដែល ប្រាក់ ខន បានលើកឡើងនោះ វិធីសាស្ត្រនេះមានភាពខុសគ្នាយ៉ាងសម្បើមពីការគំរាមកំហែងធ្វើទារុណកម្ម ឬសម្លាប់ក្រុមគ្រួសាររបស់អ្នកណាម្នាក់ ពាក់ព័ន្ធទៅនឹងការប៉ះពាល់ដល់ផ្លូវចិត្ត ដែលពួកគេមានចំពោះអ្នកជាប់ឃុំឃាំងនោះ ដែលវានៅតែជាបញ្ហាចម្រូងចម្រាស និងរឿងរ៉ាវដែលអ្នកជាប់ឃុំឃាំងអាចមិនបានដឹងនាពេលនោះ ។

---

[39] *រឿងក្តីរបស់ Maritza Urrutia ទល់នឹង ប្រទេសហ្គាតេម៉ាឡា (Guatemala)* ។ តុលាការសិទ្ធិមនុស្សអន្តរអាមេរិក ស៊េរី C លេខ ១០៣ សាលក្រមចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៣ ("រឿងក្តី *Maritza*")។

[40] ឯកសារ **E399/2**, ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៨ លេខយោងជើងទំព័រ ៦៤។ មេធាវីការពារក្តីកត់សម្គាល់ឃើញថា ឯកសារ **E3/834** (ដែលសហព្រះរាជអាជ្ញាបានយកមកសំអាងនោះ) គឺពុំបានផ្តល់ការពន្យល់ណាមួយអំពីអត្ថន័យថា "ត្រូវខំគិតអំពីមជ្ឈដ្ឋានគ្រួសារ" នោះទេ។ ឯកសារមួយទៀតដែលហាក់ចង់លើកឡើងថា "គិតអំពីមជ្ឈដ្ឋានគ្រួសារ" គឺមានន័យថា ឱ្យអ្នកជាប់ឃុំឃាំងគិតអំពីគ្រួសាររបស់ពួកគេ។ សូមមើល ឯកសារ **E3/8368** "បញ្ជីស្ថិតិរបស់សន្តិបាលស-២១៖ នយោបាយ សតិអារម្មណ៍ និងអង្គការចាត់តាំង" ដែលត្រូវបានធ្វើបច្ចុប្បន្នភាពនោះមាន ERN ភាសាខ្មែរ 00007466 និង 00007469។ ការបកប្រែទៅជាភាសាអង់គ្លេស (ERN អង់គ្លេស 00225393-94) គឺមិនត្រឹមត្រូវទេ។ ជាភាសាខ្មែរសរសេរថា ឱ្យគិតពីគ្រួសាររបស់ពួកគេ និងអាយុជីវិតរបស់ពួកគេផ្ទាល់ ចំណែកការបកប្រែជាភាសាអង់គ្លេសសរសេរថា ឱ្យគិតពីអាយុជីវិតគ្រួសាររបស់ពួកគេទៅវិញ។ យោងតាមឯកសារជាភាសាខ្មែរ មិនមានការគំរាមកំហែងដល់អាយុជីវិតគ្រួសារទេ។ ផ្នែកដែលពាក់ព័ន្ធជាភាសាខ្មែរនោះគឺ "(ឃ) អូសទាញសញ្ចេតនាឱ្យវាវិលវល់ក្នុងរង្វង់គ្រួសារប្រពន្ធកូន អាយុជីវិតវា" (ERN ភាសាខ្មែរ 00007466) "ឱ្យវានឹកឃើញគ្រួសារឪពុកម្តាយ ប្រពន្ធកូនវា អាយុជីវិតវា (ល)" (ERN ភាសាខ្មែរ 00007469)។

[41] ប្រតិចារឹកសវនាការថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១៦ (ប្រាក់ ខន សេចក្តីព្រាងប្រតិចារឹក) ទំព័រ ២៣ បន្ទាត់ ១៨ ដល់ ២៣។

24. សហព្រះរាជអាជ្ញាក៏ជំទាស់ផងដែរថា កង្វល់របស់ ឌុច ចំពោះលទ្ធភាពដែលថា កុយ ធួន អាចនឹងសម្លាប់ខ្លួនឯង បង្ហាញថា កុយ ធួន បានរងការឈឺចាប់អំពី "សភាពតានតឹងផ្លូវចិត្តដ៏ខ្លាំងក្លាបំផុត"[42]។ មេធាវីការពារក្តីយល់ឃើញថា មិនមានភ័ស្តុតាងបង្ហាញថា កង្វល់របស់ ឌុច គឺយោងទៅលើទំនោរធ្វើអត្តឃាតពិតៗរបស់ កុយ ធួន នោះទេ។ ផ្ទុយទៅវិញ ឌុច បាននិយាយថា គាត់បានណែនាំឲ្យប្រើវិធានការប្រុងប្រយ័ត្ន ក្រោយពេល កុយ ធួន បានបាត់បង់អារម្មណ៍ គ្រវែងតុ និងធ្វើឲ្យបាក់បែករបស់របរជាច្រើនទៀតនៅក្នុងបន្ទប់ឃុំខ្លួនគាត់[43]។ ហេតុដូច្នេះ យោងតាមភ័ស្តុតាងនេះ ការប្រុងប្រយ័ត្នត្រូវបានណែនាំឡើងដោយជាប់ទាក់ទងនឹងឥរិយាបទហិង្សារបស់ កុយ ធួន មិនមែនទំនោរសម្លាប់ខ្លួនឯងឡើយ។ ហេតុដូច្នេះ ក្នុងន័យនេះ ទឡ្ហីករណ៍របស់សហព្រះរាជអាជ្ញាមិនមានមូលដ្ឋានអ្វីនោះទេ។

25. សរុបមក ផ្ទុយទៅនឹងការជំទាស់តវ៉ារបស់សហព្រះរាជអាជ្ញា លក្ខខណ្ឌនៃការឃុំខ្លួន ឬការបង្ខំផ្លូវចិត្តតែមួយមុខ ដែលបានចោទប្រកាន់ ឬក៏ចំណុចទាំងពីរបញ្ចូលគ្នានោះ មិនគ្រប់គ្រាន់ដើម្បីបង្កើតបានជាការធ្វើទារុណកម្ម ដោយពុំមានហិង្សាធ្ងន់ធ្ងរណាមួយលើរូបកាយនោះបានទេ។ ហេតុដូច្នេះ នៅពេលដែលមិនមានហានិភ័យពិតប្រាកដនៃអំពើហិង្សាធ្ងន់ធ្ងរណាមួយលើរូបកាយនៅក្នុងករណីពិសេសមួយ នោះលែងមានហានិភ័យពិតប្រាកដដោយការធ្វើទារុណកម្មទៀតហើយ។ ប្រសិនបើមានហានិភ័យនៃការប្រព្រឹត្តិដោយអមនុស្សធម៌ ឬដោយបន្ទាបបន្ថោក ដោយមិនមានការធ្វើទារុណកម្ម គឺមិនគ្រប់គ្រាន់សម្រាប់ការអនុវត្តវិធានស្តីពីការច្រានចោលភ័ស្តុតាង ដូចមានចែងក្នុងមាត្រា ១៥ នៃអនុសញ្ញាស្តីពីការធ្វើទារុណកម្មនោះឡើយ[44]។ លើសពីនេះទៀត មិនមានភ័ស្តុតាងគាំទ្រដល់ធាតុផ្សំចេតនាដែលភ្ជាប់លក្ខខណ្ឌឃុំខ្លួន ដូចដែលបានចោទប្រកាន់ ទៅនឹងការទទួលបានចម្លើយរបស់អ្នកជាប់ឃុំឃាំងឡើយ[45]។ ហេតុដូច្នេះ លក្ខខណ្ឌឃុំខ្លួន និងការបង្ខិតបង្ខំផ្លូវចិត្ត ដូចដែលបានចោទប្រកាន់នោះ មិនបានបង្ហាញ

---

[42] ឯកសារ **E399/2** ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២១ លេខយោងជើងទំព័រ ៧៩។

[43] ឯកសារ **E3/347** "ចម្លើយរបស់ជនសង្ស័យ កាំង ហ្គេកអ៊ាវ *ហៅ* ឌុច ជាមួយ UNHCHR" ចុះថ្ងៃទី ៣ ខែ កក្កដា ឆ្នាំ ១៩៩៩ ("ចម្លើយរបស់ ឌុច ជាមួយ UNHCHR") អង់គ្លេស EN 00185009។

[44] *សូមមើល* កថាខណ្ឌ ៦ ខាងលើ។

[45] *សូមមើល* កថាខណ្ឌ ៧ ខាងលើ។

ឲ្យឃើញថាមានហានិភ័យពិតប្រាកដនៅក្នុងចម្លើយសារភាពណាមួយនៅ ស-២១ ទទួលបានដោយការធ្វើទារុណកម្មនោះឡើយ។ អាស្រ័យហេតុនេះ គេមិនអាចរារាំងដោយមិនឲ្យប្រើប្រាស់ចម្លើយសារភាពពី ស-២១ ដូចដែលមេធាវីការពារក្តីបានស្នើសុំនោះបានឡើយ

## ខ. ករណីរបស់ កុយ ធួន

### *(i) ស្ថានភាពឃុំឃាំងខ្លួន*

26. សហព្រះរាជអាជ្ញាជំទាស់តវ៉ាថា សូម្បីតែអវត្តមានការធ្វើរុណកម្មផ្លូវកាយក្តី ក៏កាលៈទេសៈដែល កុយ ធួន បានដឹងខ្លួននោះ បង្កើតបានជាទារុណកម្មផ្លូវចិត្តហើយ[46]។ ទោះជាយ៉ាងណាក៏ដោយ ដូចបានបង្ហាញជូនខាងក្រោមនេះ ទឡ្ហីករណ៍នេះមិនមានមូលដ្ឋានអ្វីសោះឡើយ។

- **<u>ស្ថានភាពឃុំឃាំងខ្លួន</u>**

27. ដូចដែលបានលើកឡើងខាងលើ ជាពិសេសតាមរយៈរឿងក្តីរបស់ *El-Masri*[47] ស្ថានភាពនានាដែល កុយ ធួន ប្រឈមមុខដូចដែលបានចោទប្រកាន់ ដូចជា គាត់ត្រូវបានឃុំខ្លួនក្នុងផ្ទះ គាត់ត្រូវបានដាក់ខ្នោះជើងជាប់ទៅនឹងគ្រែ ហើយគាត់ត្រូវបានបដិសេធមិនឲ្យមានឱកាសប្តឹងតវ៉ាពីករណីរបស់គាត់ និងត្រូវបានគេគត់មួយដៃដោយសារគាត់ "ប្រតិកម្ម"[48] ពិបាកនឹងបង្កើតបានជាទារុណកម្មណាស់។

28. បន្ថែមលើនេះទៀត ភ័ស្តុតាងបង្ហាញថា កុយ ធួន ត្រូវបានឃុំឃាំងនៅក្នុង "គុកពិសេស"[49] ដែល

---

[46] ឯកសារ **E399/2** ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២១។

[47] *សូមមើល* កថាខណ្ឌ ១២ ខាងលើ លេខយោងជើងទំព័រ ១៥។

[48] ឯកសារ **E399/2**៖ ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២១ លេខយោងជើងទំព័រ ៧៨។

[49] ឯកសារ **E3/347**៖ បទសម្ភាសន៍របស់ ឌុច ជាមួយ UNHCHR, ERN អង់គ្លេស 00185008។ ប្រតិចារឹកសវនាការ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៩ (កាំង ហ្កេកអ៊ាវ *ហៅ* ឌុច ឯកសារ **E3/5799**) ទំព័រ ៤៥ បន្ទាត់ ២២-២៥, ទំព័រ ៨៩ បន្ទាត់ ១១-១២។ ឯកសារ **E3/5765**៖ "កំណត់ហេតុនៃការចុះធ្វើការស៊ើបអង្កេតដល់កន្លែងកើតហេតុ" ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៨, ERN ភាសាខ្មែរ 00181336-00181336។

ស្ថិតនៅខាងក្រៅបរិវេណទួលស្លែង[50] ហើយជាពិសេស ស្ថានភាពនៅទីនោះមានលក្ខណៈងាយស្រួល មានជំនួយថ្នាំសង្កូវ ហើយការប្រព្រឹត្តិលើអ្នកទោសមានលក្ខណៈប្រសើរច្រើនជាងនៅបន្ទប់ឃុំខ្លួនធម្មតា ក្នុង ស-២១[51]។ កុយធួន មានគ្រែមួយនៅក្នុងបន្ទប់របស់គាត់ និងមានរបបអាហារដូចគ្នានឹង ឌុច ដែលជាប្រធាន ស-២១ ដែរ[52]។ ឌុច បាននិយាយទៅកាន់ កុយ ធួន យ៉ាងគួរសម[53] ហើយថែមទាំងគួរសមនៅក្នុងចំណារជាលាយលក្ខណ៍អក្សររបស់គាត់ ផ្ញើទៅកាន់ កុយ ធួន នៅលើចម្លើយដែលគាត់បានចារ ដែលនៅពេលមួយគាត់បាន "ថ្លែងអំណរគុណយ៉ាងរីករាយ" ដល់ កុយ ធួន ចំពោះព័ត៌មានដែល កុយ ធួន បានផ្តល់ឲ្យ ដែល ឌុច យល់ថាជាព័ត៌មានប្រកបដោយផ្លែផ្កា[54]។ ឌុច ក៏បានណែនាំឲ្យ ប៉ុន និងបុគ្គលិកដទៃទៀតគួរសមចំពោះ កុយ ធួន[55]។

29. ចំពោះស្ថានភាពនៃការឃុំឃាំង កុយ ធួន នៅក្នុងផ្ទះ (មុនពេលគេបញ្ជូនគាត់ទៅកាន់ ស-២១)

---

[50] ប្រតិចារឹកសវនាការ ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០០៩ (កាំង ហ្កេកអ៊ាវ *ហៅ* ឌុច ឯកសារ **E3/5795**) ទំព័រ ៨៥ បន្ទាត់ទី ២៥, ទំព័រ ៨៦ បន្ទាត់ទី ១។ ឯកសារ **E3/5692**៖ "កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ ខន" ចុះថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០០៦ ERN អង់គ្លេស 00146792។ ឯកសារ **E3/5158**៖ "កំណត់ហេតុស្តាប់ចម្លើយ ហ៊ឹម ហ៊ុយ" ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០៨ ERN អង់គ្លេស 00164451។

[51] ប្រតិចារឹកសវនាការ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៩ (កាំង ហ្កេកអ៊ាវ *ហៅ* ឌុច ឯកសារ **E3/5799**) ទំព័រ ៤៥ បន្ទាត់ទី ២២, ទំព័រ ៤៦ បន្ទាត់ទី ៦។

[52] ប្រតិចារឹកសវនាការ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៩ (កាំង ហ្កេកអ៊ាវ *ហៅ* ឌុច ឯកសារ **E3/5799**) ទំព័រ ៨៨ បន្ទាត់ទី ៨-១០។ ឯកសារ **E3/7665** "កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈុន ផល" ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៨ ERN អង់គ្លេស 00163814។

[53] ប្រតិចារឹកសវនាការ ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ *ហៅ* ឌុច ឯកសារ **E1/54.1**) ERN ខ្មែរ 00794030 (ទំព័រ ៨ បន្ទាត់ទី ១១-១៥)។ ការបកប្រែទៅជាភាសាអង់គ្លេសបាត់ចំណុចលម្អិតយ៉ាងច្រើន *សូមមើល* ERN អង់គ្លេស 00795577 (ទំព័រ ១០ បន្ទាត់ទី ១០-១៤)។

[54] ឯកសារ **E3/3856** កម្រងចម្លើយសារភាពខ្លះៗរបស់ កុយ ធួន នៅមន្ទីរស-២១ ("ចម្លើយសារភាព កុយ ធួន នៅស-២១") ERN អង់គ្លេស 00829638, ERN ភាសាខ្មែរ 00026280។

[55] ឯកសារ **E3/347** ចម្លើយរបស់ ឌុច ជាមួយ UNHCHR"), ERN អង់គ្លេស 00185009។ *សូមមើល ផងដែរ* ប្រតិចារឹកសវនាការ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៩ (កាំង ហ្កេកអ៊ាវ ហៅ ឌុច ឯកសារ **E3/5799** ទំព័រ ៤៦ បន្ទាត់ទី ៤-៥។

ដែលសហព្រះរាជអាជ្ញាជំទាស់តវ៉ាថា បានធ្វើឲ្យ កុយ ធួន មានការឈឺចាប់ផ្លូវចិត្ត[56] មានភស្តុតាងបង្ហាញថា កុយ ធួន ត្រូវបានឃុំខ្លួននៅក្នុងអាគារមួយកម្ពស់បីជាន់ ដែលគាត់អាចដើរជុំវិញផ្ទះខាងក្នុងរបបងដែលគេបានចាក់សោរ ហើយគាត់អាចនិយាយលេងជាមួយអ្នកយាមបាន។ ក្រោយមក គាត់ក៏ត្រូវបានអនុញ្ញាតឲ្យចេញទៅខាងក្រៅ ដើម្បីបានសម្រាកលំហែរបន្តិចនៅពេលល្ងាច[57]។

- **<u>ការបង្ខិតបង្ខំតាមផ្លូវចិត្ត</u>**

30. ចម្លើយរបស់ ឌុច ដែលសហព្រះរាជអាជ្ញាបានរៀបរាប់ថា ជាការបង្ហាញឲ្យឃើញពីកាលៈទេសៈ “គួរឲ្យភ័យខ្លាច” និង “បែបបំភិតបំភ័យ” ដែល កុយ ធួន ត្រូវបានសួរចម្លើយជាមួយនឹង “វិធីសាស្ត្រត្រជាក់” ហើយដែលក្នុងនោះ យោងតាមសហព្រះរាជអាជ្ញា កុយ ធួន បានទទួលរងឈឺចាប់ “ដោយការបង្ខិតបង្ខំផ្លូវចិត្តយ៉ាងខ្លាំង” គឺមានដូចខាងក្រោមនេះ៖

> ***វិធីសាស្ត្រត្រជាក់៖*** ជាវិធីសាស្ត្រមិនធ្វើទារុណកម្ម មិនមានការជេរស្តី ប៉ុន្តែ ប្រើការបញ្ចុះបញ្ចូលឃោសនា។ ឧទាហរណ៍ ពេលខ្ញុំសួរ កុយ ធួន ខ្ញុំរង់ចាំ ២ ឬ ៣ ម៉ោងមុននឹងសួរគាត់។ ខ្ញុំហៅគាត់ “បង”។ ខ្ញុំឲ្យគាត់សរសេរចម្លើយសារភាពដើម្បីខ្ញុំដាក់ជូនអង្គការ។ ខ្ញុំបានទុកពេលឲ្យគាត់សរសេរ ហើយឲ្យមនុស្សពីរនាក់នៅមើលគាត់ ដើម្បីជៀសវាងគាត់ធ្វើអត្តឃាត។ បន្ទាប់ពីបានសរសេរកន្លះទំព័រ គាត់ចាប់ផ្តើមខឹង ហើយបានហែកក្រដាស និងកាច់វ៉ែនតាគាត់ចោល។ ខ្ញុំបានទុកឲ្យគាត់ស្ងប់អារម្មណ៍សិន ហើយបន្ទាប់ពីការជជែកពិភាក្សាជាមួយគាត់ គាត់បានយល់ព្រមសរសេរចម្លើយសារភាពបន្តទៀត[58]។

មេធាវីការពារក្តីសូមលើកឡើងថា ប្រសិនបើស្ថានភាពទាំងនេះ ត្រូវបានយកមកពិចារណាថាជាការធ្វើទារុណកម្ម ទោះជាតាមផ្លូវកាយក្តី ឬតាមផ្លូវចិត្តក្តី នោះមន្ត្រីនគរបាលភាគច្រើននៅជុំវិញពិភពលោកនេះ ពិតជាត្រូវបោះបង់ការងាររបស់ខ្លួនអស់ហើយ ព្រោះថា ពួកគេពិតជាជៀសមិន

---

[56] ឯកសារ **E399/2** ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២១។

[57] ឯកសារ **E3/1604** កម្រងចម្លើយសារភាពខ្លះៗរបស់ កុយ ធួន នៅមន្ទីរស-២១ (“ចម្លើយសារភាព កុយ ធួន នៅស-២១”) ERN ភាសាខ្មែរ 00006913-30។

[58] ឯកសារ **E3/1570**៖ “កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្កេកអ៊ាវ *ហៅ* ឌុច”, ERN អង់គ្លេស 00154194-95 ដែលបានលើកមកសំអាងនៅក្នុងឯកសារ **E399/2** ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២១ លេខយោងជើងទំព័រ ៧៥។

ផុតពីការបំពេញការងារទាំងនោះ ដោយមិនមានការប្រព្រឹត្តិបទល្មើសដោយការធ្វើទារុណកម្មបាន ឡើយ។

31. ដូចគ្នានេះ ការចោទប្រកាន់របស់ព្រះរាជអាជ្ញាដែលថា កុយ ធួន ត្រូវបានគំរាមដោយការធ្វើបាប ផ្លូវកាយ[59] គឺជាការបង្ហាញភ័ស្តុតាងដោយមិនត្រឹមត្រូវ។ អ្វីដែលឌុចបានប្រាប់ កុយ ធួន គឺថា ល្បិចរបស់ កុយ ធួន ដែលព្យាយាមធ្វើឱ្យអ្នកសួរចម្លើយវាយគាត់ គឺមិនមានប្រសិទ្ធភាពឡើយ[60]។ និយាយម៉្យាងទៀត ជាជាងការប្រើប្រាស់អំពីហិង្សាផ្លូវកាយ ចេតនាដែលឌុចបានបញ្ជាក់គឺច្បាស់ ណាស់ថា ត្រូវធានាមិនឱ្យមានការវាយដំទៅលើ កុយ ធួន ឡើយ បើទោះបីជាគាត់ព្យាយាមប្រើ ល្បិចបែបណាក៏ដោយ។

32. ក្រៅពីឱ្យប៉ុនដាល់មួយដៃ ឌុចគោរពពាក្យសម្តីរបស់គាត់។ ឌុច “ហាមឃាត់ប៉ុនដាច់ខាតមិនឱ្យធ្វើ អ្វីទាំងអស់” ចំពោះ កុយ ធួន ទោះបីជា កុយ ធួន បានគ្រវែងតុ កាច់ប៊ិច បោកកែវ និងហែក ក្រដាស់ចោលច្រើនដងក៏ដោយ។ ផ្ទុយទៅវិញ ឌុចណែនាំប៉ុនឱ្យគ្រាន់តែវាយប្រហារ កុយ ធួន “ដោយពាក្យសម្តីឱ្យឈ្នះ និងយកប្រៀបលើគាត់”[61]។ ចម្លើយលើកទីមួយរបស់ កុយ ធួន ត្រូវបាន ស្រង់យកដោយមិនបាន ប្រើប្រាស់ការវាយដំទាល់តែសោះ[62]។ ការសួរចម្លើយបន្ទាប់ត្រូវបានធ្វើ ឡើង ក្នុងលក្ខណៈដូចគ្នា លើកលែងតែពេលដែលឌុច ឱ្យប៉ុនដាល់ កុយ ធួន ម្តងដើម្បីឱ្យគាត់ឈប់ ធ្វើល្បិច[63]។ ដូចដែលបានបញ្ជាក់ពីខាងលើរួចហើយ ការដាល់ត្រឹមតែម្តងមិនអាចចាត់ទុកថាជា ការធ្វើទារុណកម្មបានឡើយ[64]។ បន្ថែមលើនេះការប្រើប្រាស់កម្លាំងបាយ ដែលចាំបាច់ត្រូវតែប្រើ ដោយសារតែ អំពើផ្ទាល់របស់ជនរងគ្រោះ ជាគោលការណ៍គឺមិនត្រូវបានចាត់ទុក ថាជាការ

---

[59] ឯកសារ **E399/2,** ចម្លើយតបរបស់ព្រះរាជអាជ្ញា កថាខណ្ឌ ២១ ជើងទំព័រ ៧៦។

[60] ឯកសារ **E3/347,** ចម្លើយរបស់ ឌុច ជាមួយអង្គការ **UNHCHR**, EN 00185009។

[61] ឯកសារ **E3/347,** ចម្លើយរបស់ ឌុច ជាមួយអង្គការ **UNHCHR**, EN 00185009។

[62] ឯកសារ **E3/347,** ចម្លើយរបស់ ឌុច ជាមួយអង្គការ **UNHCHR**, EN 00185009។

[63] ឯកសារ **E3/347,** ចម្លើយរបស់ ឌុច ជាមួយអង្គការ **UNHCHR**, EN 00185009។

[64] ក្នុងករណីរបស់ កុយ ធួន គេបានដាល់គាត់ភ្លាមៗ ក្រោយពេលដែលគាត់បានចូលមកដល់ មន្ទីរ ស-២១ ហើយច្បាស់ណាស់ ថាគាត់អាចបន្តសរសេរចម្លើយរបស់គាត់ នៅពេលក្រោយមកទៀត។ មិនមានភស្តុតាងដែលថា គាត់ត្រូវទទួលរងរបួសធ្ងន់ធ្ងរ ដោយសារការដាល់នេះឡើយ។

រំលោភច្បាប់ប្រឆាំងការធ្វើទារុណកម្ម និងការប្រព្រឹត្តិអមនុស្សធម៌ ឬបន្ទាបបន្ថោកឡើយ[65]។

33. លើសពីនេះ មេធាវីការពារក្តីកត់សម្គាល់ថា សហព្រះរាជអាជ្ញាបានយោងទៅចម្លើយរបស់ ឌុច ដែលថា ពួកគេប្រើ "វិធីក្តៅ" និង "ធ្វើទារុណកម្ម" កុយ ធួន នៅពេលគាត់ប្រតិកម្ម[66]។ ត្រង់ចំណុចនេះ មេធាវីការពារក្តីជាដំបូងកត់សម្គាល់ថា ដូចដែលនឹងត្រូវពិភាក្សាលម្អិតនៅផ្នែកខាងក្រោម (កថាខណ្ឌ ៥៤) ការប្រើប្រាស់ពាក្យ "ធ្វើទារុណកម្ម" របស់សាក្សីគឺមិនអាចយកធ្វើជាការយោងតឹងរ៉ឹង ទៅលើនិយមន័យច្បាប់នៃការធ្វើទារុណកម្មឡើយ។ ការប្រើប្រាស់ទូទៅនូវពាក្យ "ធ្វើទារុណកម្ម" គឺមានន័យទូលំទូលាយខ្លាំង ហើយគ្របដណ្តប់ការប្រព្រឹត្តិដែលមិនធ្ងន់ធ្ងរ ដែលខុសពីការធ្វើទារុណកម្ម។ ទីពីរ ដូចដែលបានពិភាក្សាខាងលើ ឌុច បានឆ្លើយនៅក្នុងចម្លើយដដែលថា គាត់បានបញ្ជូនប៉ុនឲ្យទៅវាយប្រហារ កុយ ធួន ដោយពាក្យសម្តី ហើយមានម្តងនោះបានដាល់ កុយ ធួន មួយដៃ ដោយសារតែប្រតិកម្មប្រកបដោយកំហឹង។ ការវាយប្រហារដោយពាក្យសម្តី និងការដាល់មួយដៃ គឺហាក់ដូចជាស៊ីសង្វាក់គ្នាជាមួយ ការបកស្រាយរបស់ ឌុច ទៅលើ "វិធីក្តៅ" ដែលមានដូចជា "ការជេរ ការវាយ និងការធ្វើទារុណកម្មផ្សេងៗ"[67]។ ដោយគិតពីភ័ស្តុតាង និងបរិបទនៃចម្លើយរបស់ ឌុច ជារួម គឺច្បាស់ណាស់ថាអ្វីដែល ឌុច ចង់និយាយដោយពាក្យ "វិធីក្តៅ" និង "ការធ្វើទារុណកម្ម" នៅក្នុងករណីរបស់ កុយ ធួន នាពេលនេះគឺសំដៅទៅលើការវាយប្រហារដោយពាក្យសម្តី និងការដាល់មួយដៃ ដែលដូចនឹងការពិភាក្សាកន្លងមក គឺមិនអាចចាត់ទុកថាជាការធ្វើទារុណកម្មឡើយ។

34. ចំពោះការចោទប្រកាន់ពីការគំរាមកំហែងលើក្រុមគ្រួសារវិញ[68] មិនមានភ័ស្តុតាងដែលថា ឌុច បានគំរាមកំហែងធ្វើទារុណកម្ម ឬសម្លាប់ប្រពន្ធរបស់ កុយ ធួន ឡើយ ហើយក៏មិនមានភ័ស្តុតាងដែលថា ឌុច បានប្រាប់ កុយ ធួន ពីការឃុំខ្លួនប្រពន្ធរបស់គាត់ឡើយ។ ទោះជាក្នុងករណីណាក៏ដោយ ដូចដែលបានលើកឡើងខាងលើ ច្បាប់មិនបានចែងច្បាស់អំពីថាតើ ត្រឹមតែការគំរាមធ្វើបាបក្រុមគ្រួសររបស់ជនរងគ្រោះ គឺមានលក្ខណៈគ្រប់គ្រាន់ដើម្បីចាត់ទុកថាជាការធ្វើទារុណកម្ម

---

[65] រឿងក្តី *El-Masri*, កថាខណ្ឌ ២០៧។

[66] ឯកសារ E399/2, ចម្លើយតបរបស់ព្រះរាជអាជ្ញា កថាខណ្ឌ ២៤ ជើងទំព័រ ៨៩។

[67] ឯកសារ E399/2, ចម្លើយតបរបស់ព្រះរាជអាជ្ញា កថាខណ្ឌ ២៤ ជើងទំព័រ ៨៨។

[68] ឯកសារ E399/2, ចម្លើយតបរបស់ព្រះរាជអាជ្ញា កថាខណ្ឌ ២១ ជើងទំព័រ ៧២។

ឡើយ។

35. សហព្រះរាជអាជ្ញាអះអាងថា កុយ ធួន "ក្នុងឋានៈជាមន្ត្រី បកក ជាន់ខ្ពស់បំផុត ក្នុងចំណោមមន្ត្រីជាន់ខ្ពស់នានា" "មិនអាចខកខានមិនបានដឹងថា ស-២១ ជាមន្ទីរមួយសម្រាប់ធ្វើទារុណកម្ម និងការស្លាប់ពិតប្រាកដ សម្រាប់ខ្លួនគាត់ និងទំនងជាពិតលើក្រុមគ្រួសាររបស់គាត់"[69]។ មេធាវីការពារក្ដីបានឆ្លើយតបជាច្រើនលើក ចំពោះបញ្ហាមួយនេះ។ ជាដំបូង ការចោទប្រកាន់ជារួមបែបនេះ ជាពិសេសការចោទប្រកាន់ពីការដឹងឮរបស់មន្ត្រីជាន់ខ្ពស់ បក្សកុម្មុយនីស្តកម្ពុជា ព្រមទាំងការចោទប្រកាន់ពីភាពមិនអាចជៀសផុតគឺការស្លាប់របស់អ្នកជាប់ឃុំ និងក្រុមគ្រួសាររបស់ពួកគេនោះ គឺមិនមានភស្តុតាងគាំទ្រទាល់តែសោះ[70]។

36. បន្ថែមលើនេះ ប្រតិកម្មដំបូងរបស់ កុយ ធួន នៅពេលបញ្ជូនមកមន្ទីរ ស-២១ ដូចជាស្នើសុំជួបនិយាយតែជាមួយ "អង្គការ" មិននិយាយជាមួយ "ឌុច" ព្រមទាំងការគ្រវែងគុ និងបំផ្លាញរបស់របរនៅក្នុងបន្ទប់របស់គាត់ បង្ហាញថា គាត់មិនបានដឹងថា ស-២១ ដំណើរការរបៀបណាទេ។ លើសពីនេះទៀត ប្រតិកម្មទាំងអស់នេះប្រាកដណាស់ថា មិនបានបង្ហាញនូវភស្តុតាងនៃអារម្មណ៍

---

[69] ឯកសារ **E399/2**, ចម្លើយតបរបស់ព្រះរាជអាជ្ញា កថាខណ្ឌ ២១ ជើងទំព័រ ៧២។

[70] មានភស្តុតាងថាមានអ្នកជាប់ឃុំជាច្រើន ត្រូវបានដោះលែងពីមន្ទីរ ស-២១ ហើយអ្នកដែលត្រូវដោះលែងខ្លះ នៅ រស់រានមានជីវិតរហូតដល់ក្រោយឆ្នាំ ១៩៧៩ (សូមមើលជាឧទាហរណ៍ ឯកសារ **E3/8778**, របាយការណ៍ចុះផ្ទាល់ដល់ទីកន្លែង របស់មជ្ឈមណ្ឌលឯកសារកម្ពុជា, ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០០៨។ ឯកសារ **E3/8648**, "ឈ្មោះអ្នកដែលត្រូវបានដោះលែងនៅថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ១៩៧៧, កងពលធំ ៩២០" ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ១៩៧៧។ ឯកសារ **E3/7326**, មជ្ឈមណ្ឌលឯកសារកម្ពុជា, អង្គហេតុពិត ប៉ុល ពត និងអ្នកទោសនៅមន្ទីរ ស-២១ (ឆ្នាំ២០១១)។ ភស្តុតាងក៏បានបង្ហាញផងដែរថា មានមនុស្សមួយចំនួនប៉ុណ្ណោះ ដែលចូលរួមក្នុងប្រតិបត្តិការនៅមន្ទីរ ស-២១។ ឧទាហរណ៍ តាម៉ុក ដែលជាសមាជិកគណៈកម្មាការអចិន្ត្រៃយ៍ បក្សកុម្មុយនីស្តកម្ពុជា និងជាលេខាភូមិភាគនិរតីបានបញ្ជាក់ថា អ្វីដែលកើតឡើងនៅមន្ទីរ ស-២១ "គឺជាការងាររបស់ ប៉ុល ពត និងប្រធានគុកប៉ុណ្ណោះ គឺមានតែពួកគេពីរនាក់ប៉ុណ្ណោះ។ ប្រធានគុកសួរចម្លើយអ្នកទោស ហើយប៉ុល ពត ជាអ្នកសម្រេច។ នៅក្នុងគណៈកម្មការ យើងមិនបានដឹងអ្វីនោះទេ។ គណៈកម្មាការមិនមានសិទ្ធិសម្រេចអ្វី ទាក់ទងសន្តិសុខឡើយ" (ប្រតិចារឹកក្រៅផ្លូវការ និងការបកប្រែក្រៅផ្លូវការ ដោយមេធាវីការពារក្ដី ឯកសារ **E3/3907R**, ខ្សែវីដេអូនៃកិច្ចសម្ភាសន៍ជាមួយ តាម៉ុក)។ ឌុច ក៏បាននិយាយផងដែរថា សុន សេន ប្រាប់គាត់ "ម្ដងហើយម្ដងទៀតថា មិនត្រូវរាយការណ៍អំពីការសួរចម្លើយខ្លាំង ទៅនរណាផ្សេងក្រៅពីគាត់ឡើយ (សុន សេន)" (**ឯកសារ E3/347, ចម្លើយរបស់ ឌុច ជាមួយអង្គការ UNHCHR**, EN 00184996)។ លើសពីនេះទៀត មេធាវីការពារក្ដីបានកត់សម្គាល់ថា ព្រះរាជអាជ្ញាមិនបានយោងទៅរកភស្តុតាងណាមួយ ដើម្បីគាំទ្រការអះអាងយ៉ាងងងើលរបស់ខ្លួន ចំពោះចំណុចនេះឡើយ។

អស់សង្ឃឹម ឬពិបាកចិត្ត ដោយសារការដឹងឮរបស់គាត់អំពីការធ្វើទារុណកម្ម និងការស្លាប់ឡើយ។

37. លើសពីនេះទៅទៀត មេធាវីការពារក្ដីបានសង្កត់ធ្ងន់ថា ការសន្មតពីហានិភ័យពិតប្រាកដ នៃការធ្វើទារុណកម្មគឺជារឿងមួយ ប៉ុន្តែការសន្មតពីការដឹងឮ ឬសូម្បីពីចេតនានៃអំពីឧក្រិដ្ឋកម្មរបស់មន្ត្រីជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជា គឺជារឿងមួយផ្សេងទៀត។ ការសន្មតក្រោយនេះហាក់ដូចជា ការគ្រប់ដណ្ដប់ដោយមិនរឹងមាំ សម្រាប់ការចង្អុលទៅរកជនជាប់ចោទក្នុងសំណុំរឿងនេះ។ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ការសន្មតពីហានិភ័យពិតប្រាកដនៃការធ្វើទារុណកម្មនៅដំណាក់កាលនេះ គឺមិនមែនជាការរំលោភបំពានទៅលើសច្ចធារនៃនិរទោសឡើយ ព្រោះបើទោះបីជាមានការសន្មត ពីហានិភ័យពិតប្រាកដនៃឧក្រិដ្ឋកម្ម ដែលត្រូវបានប្រព្រឹត្តក៏ដោយ តែមិនមានការសន្មតពី "ពិរុទ្ធភាពរបស់ជនជាប់ចោទ ឬពីតួនាទីដែលជនជាប់ចោទបានអនុវត្ត ក្នុងការទទួលបានចម្លើយដែលកំពុងចោទជាបញ្ហាឡើយ"[71]។ ប៉ុន្តែ ការអះអាងរបស់សហព្រះរាជអាជ្ញា ជាការបណ្ដាលឲ្យអង្គជំនុំជម្រះសាលាដំបូង សន្មតអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ ឬយ៉ាងហោចណាស់អំពីតួនាទីដែលជនជាប់ចោទ បានអនុវត្តនៅក្នុងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ មុនពេលដែលពិរុទ្ធភាពនេះត្រូវបានបង្ហាញ នៅពេលបញ្ចប់សំណុំរឿង។ មេធាវីការពារក្ដីសូមលើកឡើងថា នេះគឺជាការមិនខ្វល់ខ្វាយយ៉ាងច្បាស់ក្រឡែត និងជាការរំលោភបំពានយ៉ាងពិតប្រាកដ ទៅលើសិទ្ធិជាសារវ័ន្តរបស់ជនជាប់ចោទ ដែលត្រូវទទួលបានសច្ចធារនៃនិរទោស រហូតដល់ពេលបង្ហាញនូវពិរុទ្ធភាព។

*(ii) ការចោទប្រកាន់ពីដំណាក់កាលចំនួនពីរនៃការសួរចម្លើយ*

38. សហព្រះរាជអាជ្ញាបានលើកឡើងថា មានតែការសួរចម្លើយ កុយ ធួន ចំនួនពីរលើកដំបូងប៉ុណ្ណោះដែលត្រូវបានធ្វើឡើងដោយ ឌុច ចំណែកការសួរចម្លើយផ្សេងៗទៀត ត្រូវធ្វើឡើងដោយប៉ុន ហើយថា ទោះបីជា ឌុច បានធ្វើទារុណកម្ម កុយ ធួន ដោយផ្ទាល់ ឬមិនបានធ្វើក៏ដោយ គឺមានភាពពាក់ព័ន្ធតិចតួចជាមួយចម្លើយដែលធ្វើឡើងដោយប៉ុន[72]។

39. ជាការឆ្លើយតប មេធាវីការពារក្ដីជាដំបូងសូមកត់សម្គាល់ថា ខ្លួនមិនបានពឹងផ្អែកទាំងស្រុងតែទៅ

---

[71] ឯកសារ E350/8, "សេចក្ដីសម្រេចលើភស្តុតាង ដែលបានមកដោយការធ្វើទារុណកម្ម", ថ្ងៃទី ៥ ខែ កុម្ភៈ ឆ្នាំ ២០១៦ ("សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង"), កថាខណ្ឌ ៤០។

[72] ឯកសារ E399/2, ចម្លើយតបរបស់ព្រះរាជអាជ្ញា កថាខណ្ឌ ២២។

លើចំណុចដែលឌុចមិនបានធ្វើទារុណកម្មនរណាម្នាក់ដោយផ្ទាល់នោះឡើយ។ ប៉ុន្តែមេធាវីការពារក្តីពឹងផ្អែកផងដែរទៅលើភ័ស្តុតាងដែលថា មានបញ្ជាពី សុន សេន មិនឲ្យធ្វើទារុណកម្មកុយ ធួន ហើយជាលទ្ធផលកុយ ធួន មិនត្រូវបានធ្វើទារុណកម្មឡើយ ទោះបីជាធ្វើឡើងដោយ ឌុច ឬដោយអ្នកដទៃក្តី[73]។ ដូចបានបញ្ជាក់ពីខាងលើរួចហើយ ភ័ស្តុតាងបានបង្ហាញថា ឌុច បានហាមឃាត់យ៉ាងតឹងរ៉ឹងមិនឲ្យ ប៉ុន ធ្វើបាបផ្លូវកាយលើ កុយ ធួន ឡើយ លើកលែងតែការដាល់តែម្តងប៉ុណ្ណោះ។ ឌុច ក៏បានប្រាប់អង្គជំនុំជម្រះសាលាដំបូងផងដែរថា ដោយសារតែមានបញ្ជាពីមេរបស់ខ្លួន គ្មាននរណាម្នាក់អាចប៉ះពាល់ កុយ ធួន បានឡើយ[74]។ បន្ថែមលើនេះ ចំណារនៅលើចម្លើយសារភាពនៅមន្ទីរ ស-២១ របស់ កុយ ធួន បង្ហាញថា សូម្បីតែបញ្ហាតូចតាចត្រឹមថាតើត្រូវដាក់ខ្នោះដៃ កុយ ធួន ឬថាតើត្រូវឲ្យគាត់សរសេរបន្ត ឬអត់នោះ ចាំបាច់ត្រូវតែរាយការណ៍ជូន សុន សេន ហើយទុកឲ្យ សុន សេន ជាអ្នកសម្រេច[75] គឺមនុស្សតែម្នាក់ដែលបានបញ្ជាមិនឲ្យធ្វើទារុណកម្ម កុយ ធួន។ ការនេះបង្ហាញថា ទោះបីជា ឌុច បានចូលរួមដោយផ្ទាល់ នៅក្នុងរាល់ការសួរចម្លើយ កុយ ធួន ទាំងអស់ ឬអត់ក៏ដោយ ក៏មិនមានហានិភ័យពិតប្រាកដដែលថា កុយ ធួន ត្រូវបានគេធ្វើទារុណកម្មឡើយ។

40. ទីពីរ សក្ខីកម្មរបស់ ឌុច ដែលថា គាត់លែងចង់ចូលរួមក្នុងការសួរចម្លើយ កុយ ធួន បន្ទាប់ពីការសួរចម្លើយពីរដងដំបូង ហើយគាត់បានចាត់តាំង ប៉ុន ឲ្យបន្តសួរចម្លើយនោះ គឺហាក់ដូចជាមិនមានការគាំទ្រពីភ័ស្តុតាងនៅសល់ពីសម័យនោះឡើយ[76]។ នៅក្នុងចម្លើយសារភាពរបស់ កុយ ធួន ដែល

---

[73] ឯកសារ **E399**, សារណា, កថាខណ្ឌ ១៦។

[74] ប្រតិចារឹកថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្កេកអ៊ាវ ហៅ ឌុច, ឯកសារ **E1/54.1**), KH 00794030 (ទំព័រ ៨ ជួរ ១១ ដល់១៥)។ ការបកប្រែជាភាសាអង់គ្លេស បានបាត់នូវព័ត៌មានលម្អិតជាច្រើន៖ សូមមើល EN 00795577 (ទំព័រ ១០ ជួរ ១០ ដល់ ១៤)។

[75] ឯកសារ **E3/1604**, ចម្លើយសារភាពរបស់ កុយ ធួន នៅមន្ទីរ ស-២១, EN 00773088, KH 00006757។ ចំណារចុះថ្ងៃទី ៨ ខែ មីនា ឆ្នាំ ១៩៧៧ ហើយមិនមានចុះហត្ថលេខាឡើយ។ ប៉ុន្តែអក្សរសរសេរដៃគឺច្បាស់ណាស់ជាអក្សររបស់ សុន សេន។ ដើម្បីប្រៀបធៀបសូមមើលជាឧទាហរណ៍ ឯកសារ **E3/1562**, KH 00174764; ឯកសារ **E3/1127**, KH 00162487; ឯកសារ **E3/1047**, KH 00002455។

[76] *សូមមើល* ឯកសារ **E399/2**, ចម្លើយតបរបស់ព្រះរាជអាជ្ញា កថាខណ្ឌ ២២ ជើងទំព័រ ៨២។

មាននៅក្នុងសំណុំរឿង មានចំណារតែមួយគត់របស់ ប៊ុន ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ១៩៧៧[77]។ ផ្ទុយទៅវិញចំណាររបស់ ឌុច ហាក់ដូចជាមាននៅពេញចម្លើយសារភាព ដែលការនេះបង្ហាញថា គាត់នៅតែចូលរួមដោយផ្ទាល់ក្នុងការសួរចម្លើយ បន្ទាប់ពីខែ កុម្ភៈ ឆ្នាំ ១៩៧៧[78]។ ជាឧទាហរណ៍ នៅក្នុងចំណារមួយដែលសរសេរនៅលើទំព័រមួយ ក្នុងចម្លើយសារភាពរបស់ កុយ ធួន នៅថ្ងៃទី ៣ ខែ មេសា ឆ្នាំ ១៩៧៧ ឌុចបានសរសេរដែលបង្ហាញថាពេលមួយ ក្រោយថ្ងៃទី ៣ ខែ មេសា ឆ្នាំ ១៩៧៧៖ "[...]តែអានកំណត់នេះចេះតែរង្កៀសក្នុងអារម្មណ៍។ [...] ដល់ទៅសួរបញ្ជាក់វា វាថា[...]"[79]។ ការដែលឌុចទៅសួរបញ្ជាក់ដោយផ្ទាល់ជាមួយ កុយ ធួន បង្ហាញថា ឌុច នៅតែចូលរួមដោយផ្ទាល់ និងសកម្ម ក្នុងការសួរចម្លើយ កុយ ធួន នៅក្នុងខែ មេសា ឆ្នាំ ១៩៧៧។

41. ផ្អែកលើការបកស្រាយខាងលើ មេធាវីការពារក្តីសូមលើកឡើងថា មិនមានហានិភ័យពិតប្រាកដដែលថា ចម្លើយសារភាពណាមួយរបស់ កុយ ធួន ត្រូវបានធ្វើឡើងដោយទារុណកម្មឡើយ។

### *(iii) ភាពអាចជឿជាក់បានរបស់ ឌុច និងការប្រើប្រាស់ពាក្យ "ទារុណកម្ម"*

42. សហមេធាវីនាំមុខបានលើកទឡ្ហីករណ៍ថា ដោយសារតែ ឌុច ត្រូវបានផ្តន្ទាទោសពីបទធ្វើទារុណកម្ម តាមរយៈសហឧក្រិដ្ឋកម្មរួម ភ័ស្តុតាងរបស់ ឌុច ដែលថាមិនមានការប្រើប្រាស់ទារុណកម្ម គឺមិនអាចបដិសេធលើហានិភ័យពិតប្រាកដនៃការធ្វើទារុណកម្មឡើយ[80]។

43. ទីមួយ មេធាវីការពារក្តីសូមកត់សម្គាល់ថា ឌុច មិនត្រូវបានចោទប្រកាន់ ឬផ្តន្ទាទោសពីបទប្រព្រឹត្តអំពើទារុណកម្ម តាមរយៈផ្លូវកាយឡើយ[81]។ ហេតុដូច្នេះ មិនមានសំអាងហេតុគួរឲ្យជឿជាក់ ដែល

---

[77] ឯកសារ **E3/1604,** ចម្លើយសារភាពរបស់ កុយ ធួន នៅមន្ទីរ ស-២១, EN 00776989, KH 00005794។

[78] ឯកសារ **E3/3856,** ចម្លើយសារភាពរបស់ កុយ ធួន នៅមន្ទីរ ស-២១, ឯកសារ **E3/3856,** ចម្លើយសារភាពរបស់ កុយ ធួន នៅមន្ទីរ ស-២១, KH 00026279; ឯកសារ **E3/1604,** ចម្លើយសារភាពរបស់ កុយ ធួន នៅមន្ទីរ ស-២១, KH 00006772, 00006858, 00006869, 00006874, 00006876, 00006878, 00006906។

[79] ឯកសារ **E3/1604,** ចម្លើយសារភាពរបស់ កុយ ធួន នៅមន្ទីរ ស-២១, EN 00773114, KH 00006869។ ចំណារមិនមានចុះហត្ថលេខាឡើយ។ ប៉ុន្តែច្បាស់ណាស់ថាអក្សរសរសេរដៃ គឺជារបស់ឌុច។ ដើម្បីប្រៀបធៀប សូមមើលជាឧទាហរណ៍ ឯកសារ **E3/3856**, KH 00026279។

[80] ឯកសារ **E399/1,** ចម្លើយតបរបស់សហមេធាវីនាំមុខ, កថាខណ្ឌ ១៤។

[81] សាលក្រម សំណុំរឿង ០០១, កថាខណ្ឌ ៤៨២ (ជើងទំព័រ ៨៤៧), ៤៨៦។

ធ្វើឲ្យមានវិមតិសង្ស័យទៅលើភ័ស្តុតាងរបស់គាត់ ទាក់ទងថាតើគាត់បានធ្វើទារុណកម្មដោយផ្ទាល់ ឬអត់នោះឡើយ។ លើសពីនេះទៀត ទាក់ទងសហឧក្រិដ្ឋកម្មរួម ឌុច មិនដែលបដិសេធថាមិនមាន "ទារុណកម្ម" នៅមន្ទីរ ស-២១ ឡើយ លើកលែងតែករណីជាក់ស្តែងមួយចំនួនតូច ដូចជាករណី កុយ ធួន[82]។ ឌុច ក៏មិនដែលបដិសេធការចោទប្រកាន់ពីការទទួលខុសត្រូវរបស់គាត់ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តដោយអ្នកនៅក្រោមបង្គាប់គាត់ឡើយ។ វាមិនមានន័យអ្វីឡើយដែលគាត់ត្រូវកុហក អំពីហេតុការណ៍តែមួយ នៅពេលដែលគាត់ព្រមទទួលស្គាល់ថា "ទារុណកម្ម" ត្រូវបានប្រើប្រាស់សឹងតែគ្រប់ករណីទាំងអស់នោះ។ ការចូលរួមដោយផ្ទាល់របស់ ឌុច ក្នុងការសួរចម្លើយ កុយ ធួន គឺមិនមែនជាមូលហេតុដែលគួរឲ្យជឿជាក់ ក្នុងការបដិសេធភ័ស្តុតាងរបស់គាត់ដែរ។ មានហេតុផលពីរយ៉ាងគឺ ទីមួយ ឌុចមិនត្រូវបានចោទប្រកាន់ពីការប្រព្រឹត្តិដោយផ្ទាល់ឡើយ។ ទីពីរ បើទោះបីជាមានបញ្ហាលើកិត្តិយសរបស់គាត់ ជាជាងការទទួលខុសត្រូវព្រហ្មទណ្ឌក៏ដោយ ក៏មិនមានមូលហេតុអ្វីដែល ឌុច ត្រូវកុហកដើម្បីការពារកិត្តិយសរបស់បុគ្គលដទៃ ដែលបានចូលរួមក្នុងការសួរចម្លើយ កុយ ធួន ដូចជា ប៊ុន នោះដែរ។ ហេតុដូច្នេះ ទឡ្ហីករណ៍របស់សហមេធាវីនាំមុខមិនធ្វើឲ្យប៉ះពាល់ដល់ភ័ស្តុតាងដែលថា កុយ ធួន មិនត្រូវបានធ្វើទារុណកម្មឡើយ ទោះបីជាធ្វើឡើងដោយ ឌុច ឬដោយអ្នកដទៃ។

44. សហមេធាវីនាំមុខក៏បានលើកឡើងផងដែរថា ការប្រើប្រាស់ពាក្យ "ទារុណកម្ម" របស់ ឌុច មិនអាចសន្និដ្ឋថាជាការអនុវត្តន៍និយមន័យច្បាប់ សម្រាប់ពាក្យទារុណកម្មឡើយ ហេតុដូច្នេះគឺមិនអាចបដិសេធពីហានិភ័យពិតប្រាកដ[83]។ មេធាវីការពារក្តីយល់ស្របជាគោលការណ៍ថា ការប្រើប្រាស់ពាក្យ "ទារុណកម្ម" របស់សាក្សី គឺមិនអាចធៀបជាមួយការប្រើប្រាស់ "ទារុណកម្ម" នៅក្នុងន័យច្បាប់ឡើយ។ ចំណុចនេះប្រាកដជាដូច្នេះមែន ដោយសារតែវាលេចចេញពីសក្ខីកម្មរបស់ ប្រាក់ ខន ដែលថាពេលខ្លះគាត់ប្រើប្រាស់ពាក្យ "ទារុណកម្ម" សំដៅទៅលើការវាយដោយមែក

---

[82] មេធាវីការពារក្តីសូមលើកឡើងថា មាន "ករណីលើកលែង" ច្រើនជាងអ្វីដែល ឌុច បានលើកឡើង ព្រោះបើទោះបីជា ឌុច បានដឹងឮអំពីករណីពីរ បីនេះក៏ដោយ តែគាត់មិនបានដឹងទាំងស្រុងនូវករណីទាំងអស់ផ្សេងទៀត នៅមន្ទីរ ស-២១ ឡើយ។ ទោះជាយ៉ាងនេះក្តី ការនេះមិនបានប៉ះពាល់ដល់ទឡ្ហីករណ៍របស់មេធាវីការពារក្តី ដែលទាក់ទងនឹងអាកប្បកិរិយារបស់ ឌុច ព្រមទាំងការដឹងឮរបស់គាត់ អំពីករណីជាក់ស្តែងរបស់ កុយ ធួន ឡើយ គឺគ្រាន់តែទាក់ទងនឹងភាពត្រឹមត្រូវ នៃការដឹងឮរបស់គាត់ ចំពោះករណីដទៃទៀតប៉ុណ្ណោះ។

[83] ឯកសារ **E399/1**, ចម្លើយតបរបស់សហមេធាវីនាំមុខ, កថាខណ្ឌ ១៤។

ឈើទំហំប៉ុនបិច ហើយដែលការវាយនេះបន្សល់ត្រឹមស្នាមវាយ ដែលនឹងបាត់ទៅវិញ "ក្នុងរយៈពេលមួយ ឬពីរថ្ងៃ"[84]។ ការប្រព្រឹត្តិបែបនេះ បើយោងតាមការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០១ វិញ គឺមិនអាចឈានដល់កម្រិតអប្បរមានៃភាពធ្ងន់ធ្ងរ ដែលបង្កើតបានជាការធ្វើទារុណកម្មឡើយ[85]។ ប្រធានអង្គជំនុំជម្រះសាលាដំបូងក៏បានកត់សម្គាល់ផងដែរថា នៅក្នុងភាសាខ្មែរពាក្យ "ទារុណកម្ម" អាចប្រើប្រាស់សម្រាប់សូម្បី ឪពុកម្តាយប្រដៅកូន ហើយពាក្យនេះ "មិនអាចកំណត់តាមផ្លូវច្បាប់ថាជាទារុណកម្ម" ឡើយ[86]។ ហេតុដូច្នេះ ន័យទូទៅនៃពាក្យ "ទារុណកម្ម" ក្នុងភាសាខ្មែរ ហាក់ដូចជាទូលំទូលាយជាងពាក្យច្បាប់ ហើយអាចសំដៅទៅលើការប្រព្រឹត្តិដែលខុសពីការធ្វើទារុណកម្ម។ ដោយសារហេតុនេះហើយ នៅពេលដែលសាក្សីអង្គហេតុទូទៅអះអាងថា មាន "ទារុណកម្ម" គឺមិនមានទាញចេញនូវការសន្និដ្ឋានពិតប្រាកដណាមួយដែលថា តើមានទារុណកម្មក្នុងន័យច្បាប់កើតឡើង ដែរឬយ៉ាងណានោះឡើយ។ ទោះជាបែបនេះក្តី នៅពេលដែលសាក្សីបែបនេះនិយាយថា មិនមាន "ទារុណកម្ម" គឺប្រាកដជាអាចសន្និដ្ឋានបានថា ការនេះមានន័យថា ទារុណកម្មក្នុងន័យច្បាប់ពិតជាមិនបានកើតឡើងឡើយ ដោយសារតែពាក្យទូទៅនៃ "ទារុណកម្ម" គឺមានន័យទូលំទូលាយគ្រប់ដណ្តប់ទៅលើ សូម្បីតែន័យច្បាប់។ ហេតុដូច្នេះ មេធាវីការពារក្តីសូមលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងអាចចាត់ទុក ចម្លើយរបស់ ឌុច ដែលថាមិនមានការធ្វើ "ទារុណកម្ម" ទៅលើ កុយ ធួន ធ្វើជាភស្តុតាងថាមិនមានការធ្វើទារុណកម្ម ក្នុងន័យច្បាប់ឡើយ។

*(iv)* ***ចំណារ***

45. សហព្រះរាជអាជ្ញាបានយោងលើចំណារចំនួនពីរនៅលើចម្លើយសារភាពរបស់ កុយ ធួន ដែលលើកឡើងថា កុយ ធួន គ្រាន់តែបានឆ្លើយក្រោយពី [យើង] "ចោះ" ម្តង[87] និងក្រោយមកម្តង

---

[84] ប្រតិចារឹកថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១៦ (ប្រាក់ ខន, សេចក្តីព្រាង ប្រតិចារឹក), ទំព័រ ៣ ជួរ ២០ ដល់ ២៥។ ទំព័រ ៦ ជួរ ២៤ – ទំព័រ ៨ ជួរទី ៣។ ទំព័រ ២៣ ជួរ ៩ ដល់ ១០។

[85] សាលក្រម សំណុំរឿង ០០១, កថាខណ្ឌ ២៤១។

[86] ប្រតិចារឹកថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១៦ (ប្រាក់ ខន, សេចក្តីព្រាង ប្រតិចារឹក), ទំព័រ ៦៦ ជួរ ១៩ – ទំព័រ ៦៧ ជួរទី ៥។

[87] ឯកសារ **E3/1604** ចម្លើយសារភាព ស-២១ របស់ កុយ ធួន EN 00769831, KH 00006159។

ទៀត[88]។ សហព្រះរាជអាជ្ញាតវ៉ាថា យោបល់ទាំងនេះបង្ហាញអំពីការប្រើប្រាស់ទារុណកម្មលើរូបរាងកាយមកលើ កុយ ធួន[89]។ ក៏ប៉ុន្តែ សហព្រះរាជអាជ្ញាខកខានមិនបានទទួលស្គាល់ថា នៅក្នុងចំណារទីពីរ ប្រយោគទាំងមូលសរសេរដូចខាងក្រោម៖

> វាមិនព្រមសារភាពរហូតយើង [ចោះ]ម្ដងទៀត*ហើយដាក់ប្លាកថា* "រក្សាការសម្ងាត់ដូចរក្សាប្រស្រីភ្នែកទៀតឬ?" [ហើយ] "ឆ្លើយមួលបង្កាច់ឈ្មោះណាខ្លះ"?[90] (គូសបញ្ជាក់បន្ថែម)

"ចោះ" *នៅក្នុងចម្លើយសារភាពទាំងពីរ* ច្បាស់ណាស់ពុំមានន័យដោយត្រង់ថា ចោះប្រហោងលើខ្លួនប្រាណរបស់បុគ្គលណាម្នាក់នោះទេ។ មេធាវីការពារក្ដីក៏កត់សម្គាល់ផងដែរថា "ប្រស្រីភ្នែក" នៅក្នុងភាសាខ្មែរត្រូវបានប្រើប្រាស់ជារឿយៗជាពាក្យប្រៀបធៀបថាជារបស់សំខាន់ ឬមានតម្លៃ។ ដូច្នេះ បរិបទនៃភាសានៅក្នុងចំណារទាំងពីរនោះដែលទាំងពីរចុះថ្ងៃទី ៩ ខែ មេសា ឆ្នាំ ១៩៧៧ និងដែលទំនងបានសរសេរដោយបុគ្គលតែម្នាក់នោះបង្ហាញយ៉ាងច្បាស់ថា ពាក្យ "ចោះ" សំដៅលើការវាយប្រហារផ្នែកពាក្យសម្ដីទំនងជាលើភាពទន់ខ្សោយនៅក្នុងចម្លើយសារភាពរបស់ កុយ ធួន ពុំមែនជាទារុណកម្មលើរូបរាងកាយនោះទេ។

46. ម្យ៉ាងវិញទៀត មេធាវីការពារក្ដីកត់សម្គាល់ឃើញថា សំណេរដៃនៃចំណារទាំងពីរនេះបង្ហាញថាជារបស់ សុន សេន *ហៅ* ខៀវ[91]។ គាត់គឺជាបុគ្គលតែម្នាក់គត់ដែលបានផ្ដល់បញ្ជាតឹងរ៉ឹងកុំឲ្យធ្វើទារុណកម្ម កុយ ធួន[92]។ ដូច្នេះ វាទំនងជាពុំអាចទេថា ចំណារទាំងពីរនេះបង្ហាញជាភ័ស្តុតាងនូវការធ្វើទារុណកម្មលើរូបរាងកាយនោះ។

---

[88] ឯកសារ **E3/1604** ចម្លើយសារភាព ស-២១ របស់ កុយ ធួន EN 00773153, KH 00006930។

[89] ឯកសារ **E399/2** ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៣ លេខយោងជើងទំព័រ ៨៤, ៨៥។

[90] ឯកសារ **E3/1604** ចម្លើយសារភាព ស-២១ របស់ កុយ ធួន EN 00773153, KH 00006930។ មេធាវីការពារក្ដីកត់សម្គាល់ថា សំណៅបកប្រែជាភាសាអង់គ្លេសបានប្រើប្រាស់ពាក្យ "mention" ចំណែកនៅក្នុងភាសាខ្មែរ វាជាពាក្យតែមួយ (ចោះ) ដូចគ្នានឹងពាក្យដែលបានប្រើប្រាស់នៅក្នុងចំណារលើទំព័រជាភាសាខ្មែរ KH 00006159 ដែលមានន័យថា "ចោះ"។

[91] សម្រាប់ការប្រៀបធៀប *សូមមើល ខ.* ឯកសារ **E3/1562** KH 00174764, KH 00006757។ ឯកសារ E3/1047 KH 00002455។

[92] *សូមមើល* ឯកសារ **E399** សំណើសុំ កថាខណ្ឌ ១៦។

47. ចំពោះចំណារទីបីដែលសហព្រះរាជអាជ្ញាបានយោង ពោលគឺ ចំណារទាក់ទងនឹងឃ្នោះដៃ[93] មេធាវីការពារក្ដីសូមលើកចំណុចសន្និដ្ឋានចំនួនបី។ ចំណុចទីមួយ ការប្រើប្រាស់ឃ្នោះដៃដូចបានពិពណ៌នានៅក្នុងចំណារនេះពិតណាស់ពុំមែនជាទារុណកម្មនោះទេ។ ចំណុចទីពីរ ចំណារនេះហាក់ដូចជាមកពី សុន សេន ដែលបានចេញបញ្ជាដោយផ្ទាល់មិនឱ្យ "ធ្វើទារុណកម្ម" កុយ ធួន។ ចំណុចទីបី ករណីដែលថា កុយ ធួន អាចចរចាលក្ខខណ្ឌដូចជាការប្រើប្រាស់ឃ្នោះដៃ មិនថា គាត់ចរចារបានជោគជ័យដែរឬក៏អត់នោះ បង្ហាញថា គាត់ពុំស្ថិតនៅក្រោមការបង្ខំ ឬ ការឈឺចាប់ផ្នែករាងកាយ ឬ ផ្លូវចិត្តធ្ងន់ធ្ងរនោះឡើយ។

## *(v) ភាពអាចទុកចិត្តបាននៃចម្លើយសារភាព*

48. សហមេធាវីនាំមុខលើកឡើងបញ្ហានៃភាពអាចទុកចិត្តបាននៃចម្លើយសារភាពរបស់ កុយ ធួន[94]។ មេធាវីការពារក្ដីសន្និដ្ឋានថា ភាពអាចទុកចិត្តបានគឺជាបញ្ហាដែលអង្គជំនុំជម្រះសាលាដំបូងពិចារណារួមគ្នាលើគ្រប់ភស្តុតាងនៅចំពោះមុខខ្លួន។ ដូច្នេះ វាពុំរារាំងភាគីមិនឱ្យប្រើប្រាស់ភស្តុតាងនៅក្នុងការជំនុំជម្រះដំណាក់កាលនេះទេ។ ជាការពិត ដូចសភាជាន់ខ្ពស់បានលើកឡើងនៅក្នុងរឿងក្ដី *A និងអ្នកផ្សេងទៀត* ចម្លើយដែលបានធ្វើឡើងដោយពុំមានការស្ម័គ្រចិត្តពុំមែនតែងតែមិនអាចទុកចិត្តបានរហូតនោះទេ ជាពិសេសនៅពេលចម្លើយទាំងនោះស៊ីសង្វាក់គ្នាជាមួយនឹងភស្តុតាងជាក់ស្ដែង ហើយបញ្ហាបារម្ភលើភាពអាចទុកចិត្តបានពុំមែនជាហេតុផលតែមួយ ឬ ហេតុផលកំណត់សម្រាប់ដកចេញចម្លើយទាំងនេះ អនុលោមតាមមាត្រា ១៥ នៃអនុសញ្ញាស្ដីពីការប្រឆាំងទារុណកម្មនោះឡើយ[95]។

---

[93] ឯកសារ **E3/1604** ចម្លើយសារភាព ស-២១ របស់ កុយ ធួន EN 00773088, KH 00006757។ ឯកសារ **E399/2** ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៣ លេខយោងជើងទំព័រ ៨៦។

[94] ឯកសារ **E399/1** ចម្លើយតបរបស់សហមេធាវីនាំមុខ កថាខណ្ឌ ១៥។

[95] រឿងក្ដី *A និងអ្នកផ្សេងទៀត ទល់នឹង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ* សភាជាន់ខ្ពស់ [២០០៥] សភាជាន់ខ្ពស់អង់គ្លេស (ឯកសារភ្ជាប់លេខ ១២) កថាខណ្ឌ ១៦-១៧, ១១២។ "ជាធម្មតា គ្មានភស្តុតាងណាច្បាស់ជាងនឹងអំពីភាពអាចទុកចិត្តបាននៃចម្លើយដែលពុំបានលើកឡើងដោយការស្ម័គ្រចិត្តជាងសំអាងហេតុនៃភស្តុតាងដែលជាលទ្ធផលរកឃើញដោយផ្ទាល់ចេញពីចម្លើយនោះទេ" (កថាខណ្ឌ ១៧)។ "ការប្រើប្រាស់នៃភស្តុតាងបែបនេះត្រូវបានដកចេញដោយពុំមែនដោយសារមូលដ្ឋាននៃភាពមិនអាចទុកចិត្តបាននោះទេ ប៉ុន្តែដោយសារមូលដ្ឋាននៃភាពព្រៃផ្សៃ អនីត្យានុកូលភាព និងភាពអមនុស្សធម៌របស់វា ពោលគឺ ប្រសិនបើនេះជា

## គ. ករណី យឹម សម្បត្តិ

49. សហមេធាវីនាំមុខព្យាយាមបន្ថយតម្លៃទឡ្ហីករណ៍របស់មេធាវីការពារក្តី ដោយបានយោងលើសក្ខីកម្មរបស់ ឌុច ដែលថា ទោះបីជាបញ្ជាមកពីមេរបស់គាត់មិនឲ្យ "ធ្វើទារុណកម្ម" យឹម សម្បត្តិ ក៏ដោយ ក៏ក្រោយមក យឹម សម្បត្តិ ត្រូវបានរងការធ្វើ "ទារុណកម្ម" ដដែល[96]។ មេធាវីការពារក្តីកត់សម្គាល់ឃើញថា ទោះបីជាការបកប្រែជាភាសាអង់គ្លេសលើសក្ខីកម្មរបស់ ឌុច ប្រើប្រាស់ពាក្យ "ទារុណកម្ម" ក៏ដោយ ក៏ពាក្យពេចន៍ជាភាសាខ្មែរនឹងពាក្យនេះដែល ឌុច បានប្រើប្រាស់គឺពាក្យ "វ៉ៃ"[97]។ ដូចអង្គជំនុំជម្រះសាលាដំបូងបានសម្រេចនៅក្នុងសំណុំរឿង ០០១ ការវាយដំមិនអាចចាត់ទុកជាទារុណកម្មនោះទេ លើកលែងតែភាពធ្ងន់ធ្ងររបស់វាឈានដល់លក្ខខណ្ឌកម្រិតអប្បបរមា[98]។ យោងតាម ឌុច សុន សេន បានចេញបញ្ជាមិនឲ្យធ្វើទារុណកម្ម យឹម សម្បត្តិ នៅក្នុងអំឡុងពេលសួរចម្លើយពីព្រោះ "សុន សេន មិនចង់ឲ្យខ្លួនគាត់ស្ថិតនៅក្នុងជំហរមួយដែលចាញ់ប្រៀបចាន់ ចក្រី នេះទេ ដែលអាចបន្ទោស សុន សេន ថាបានប្រើទារុណកម្មដើម្បីទទួលបានចម្លើយសារភាព"[99]។ ឌុច បាននិយាយថា "ការសួរចម្លើយគាត់បានប្រព្រឹត្តទៅដោយមិនមានធ្វើទារុណកម្ម ហើយគេបានថតរូបទៀតផងដើម្បីបង្ហាញថាមិនមានការធ្វើទារុណកម្មនោះទេ"[100]។ នៅពេលពិនិត្យមើលភស្តុតាងរួមគ្នា មេធាវីការពារក្តីសន្និដ្ឋានថា បើទោះជាការពិតទៅ យឹម សម្បត្តិ ត្រូវបានវាយដំក៏ដោយ ក៏ការវាយដំនោះមិនអាច

---

ការជំទាស់តែមួយគត់លើចម្លើយនេះ វានឹងពាក់ព័ន្ធចំពោះទម្ងន់របស់ចម្លើយនោះ ពុំមែនភាពអាចទទួលយកបានរបស់វានោះ" (កថាខណ្ឌ ១១២)។

[96] ឯកសារ **E399/1**, ចម្លើយតបរបស់សហមេធាវីនាំមុខ កថាខណ្ឌ ១៨។

[97] ប្រ. ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១២ (កាំង ហ្គេកអ៊ាវ *ហៅ* ឌុច ឯកសារ **E1/54.1**) KH 00794030 (ទំព័រ ៨ ជួរទី១៦-១៩) EN 00795577 (ទំព័រ ១០ ជួរទី ១៥-១៩)។

[98] សាលក្រមលើសំណុំរឿង ០០១ កថាខណ្ឌ ២៤១។

[99] ឯកសារ **E319/42.3.1**, កំណត់ហេតុនៃការសួរចម្លើយ ឌុច, A 13, ERN 01213411, ឯកសារ **E3/356** "កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ *ហៅ* ឌុច ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០០៨" ("កំណត់ហេតុនៃការស្តាប់ចម្លើយ ឌុច ឆ្នាំ២០០៨") ERN 00242900។

[100] ឯកសារ **E3/356** កំណត់ហេតុនៃការស្តាប់ចម្លើយ ឌុច ឆ្នាំ ២០០៨ ERN 00242900 គូសបញ្ជាក់បន្ថែម។ *សូមមើលផងដែរ* ឯកសារ **E319/42.3.1**, កំណត់ហេតុនៃការសួរចម្លើយ ឌុច, A 13, ERN 01213411។

មានលក្ខណៈធ្ងន់ធ្ងរបរហូតអាចចាត់ទុកជាទារុណកម្មនោះទេ ដោយសារ ឌុច ជឿទុកចិត្តថាបាន ថតរូបជាភស្តុតាងបង្ហាញ ចាន់ ចក្រី។

50. ទាក់ទងនឹងទឡ្ហីករណ៍របស់សហព្រះរាជអាជ្ញាថា សេចក្តីសង្ខេបនៃចម្លើយសារភាពរបស់អ្នកផ្សេងដែលរួមមាននៅក្នុងចម្លើយសារភាពរបស់ យឹម សម្បត្តិ មិនគួរត្រូវបានប្រើប្រាស់ដោយមិនមានភស្តុតាង ដែលបដិសេធហានិភ័យជាក់ស្តែងនៃទារុណកម្មនៅក្នុងករណីរបស់ពួកគេ[101] មេធាវីការពារក្តីយល់ស្របថា ករណីនេះយុត្តិធម៌ ហើយស្របជាមួយនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល និងអង្គជំនុំជម្រះសាលាដំបូង។ ក៏ប៉ុន្តែ មេធាវីការពារក្តីសូមរក្សាសិទ្ធិពិនិត្យមើលបញ្ហានេះឡើងវិញ ប្រសិនបើនាពេលក្រោយមក ខ្លួនរកឃើញភស្តុតាងដែលច្រានចោលហានិភ័យជាក់ស្តែងនៃទារុណកម្មនៅក្នុងករណីជាក់លាក់របស់បុគ្គលទាំងនេះផ្សេងទៀត។

51. មេធាវីការពារក្តីក៏កត់សម្គាល់ឃើញផងដែរថា វាមានភស្តុតាងបង្ហាញថា យឹម សម្បត្តិ ត្រូវបានយកចេញពីកន្លែងឃុំខ្លួន "ក្បាលថ្នល់" ទៅឃុំខ្លួននៅកន្លែងដែលមិនស្គាល់ឈ្មោះមួយនៅថ្ងៃទី ៤ ខែមេសា ឆ្នាំ ១៩៧៦[102]។ អង្គហេតុដែលមានការព្រមព្រៀងគ្នាមួយនៅក្នុងសំណុំរឿង ០០១ គឺ "នៅខែ មេសា ឆ្នាំ ១៩៧៦ តាមសេចក្តីសម្រេចរបស់ [ឌុច] អ្នកជាប់ឃុំនៅមន្ទីរ ស-២១ ត្រូវបានយកទៅឃុំឃាំងក្នុងបរិវេណវិទ្យាល័យពញាយ៉ាត [...] ដែលជាបរិវេណនៃសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងសព្វថ្ងៃនេះ"[103]។ ផ្អែកលើភស្តុតាងនេះ ករណីថាតើ យឹម សម្បត្តិ ត្រូវបានឃុំខ្លួននៅទួលស្លែង ឬ នៅកន្លែងផ្សេងនៅតែជាបញ្ហាសង្ស័យនៅឡើយ។ ដូច្នេះ លក្ខខណ្ឌនៅទួលស្លែងអាចពុំជាប់ទាក់ទងទៅនឹងការកំណត់នៃលក្ខខណ្ឌឃុំខ្លួន យឹម សម្បត្តិ ឡើយ។

## ឃ. ករណី ជា ណុន

52. សហព្រះរាជអាជ្ញាតវ៉ាថា ចំណារលើចម្លើយសារភាពរបស់ ជា ណុន សរសេរថា "វាសរសេរមុនពេលធ្វើទារុណកម្ម" ត្រឹមតែលើកឡើងក្នុងប៉ុន្មានទំព័រដំបូងនៅក្នុងចម្លើយសារភាពរបស់ ជា ណុន ដូច្នេះ វាពុំច្រានចោលហានិភ័យជាក់ស្តែងនៃទារុណកម្មទាក់ទងផ្នែកសេសសល់ផ្សេងទៀតនៅក្នុង

---

[101] ឯកសារ **E399/2** ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៦។

[102] មជ្ឈមណ្ឌលឯកសារកម្ពុជាលេខ **D06865** "បញ្ជីឈ្មោះអ្នកទោស" គ្មានកាលចុះបរិច្ឆេទ ទំព័រ ៦ KH 01012815។

[103] *សូមមើល* សាលក្រមលើសំណុំរឿង ០០១ កថាខណ្ឌ ១៣៥។

ចម្លើយសារភាពរបស់គាត់នោះទេ[104]។

53. ផ្ទុយទៅវិញ មេធាវីការពារក្ដីកត់សម្គាល់ឃើញថា វាមានភ័ស្ដុតាងបង្ហាញ អ្នកសួរចម្លើយបានចងក្រងចម្លើយសារភាពដែលបានសរសេរដោយអ្នកជាប់ឃុំ នៅពេលការសួរចម្លើយពួកគេបានបញ្ចប់ អ្នកសួរចម្លើយចម្លងពីរបីច្បាប់ និងបញ្ជូនកម្រងចម្លើយសារភាពទាំងនោះទៅថ្នាក់លើរបស់ពួកគេ[105]។ មេធាវីការពារក្ដីកត់សម្គាល់ឃើញថា ចំណារដែលចោទជាបញ្ហានេះបានដាក់ភ្លាមៗ នៅក្រោយទំព័រគម្របនៃចម្លើយរបស់ ជា ណុន ដែលបានចងក្រងនោះ ហើយត្រូវបានសរសេរក្នុងទម្រង់មួយខុសគ្នាទាំងស្រុងពីចំណារនៅលើទំព័រគម្របនៃផ្នែកនីមួយៗ[106]។ ដូច្នេះ មេធាវីការពារក្ដីសន្និដ្ឋានថា វាបង្ហាញច្បាស់ថា ចំណារដែលចោទជាបញ្ហានេះមានគោលបំណងអនុវត្តចំពោះកម្រងចម្លើយសារភាពរបស់ ជា ណុន ជារួម ពុំមែនចំពោះតែប៉ុន្មានទំព័រដំបូងនោះឡើយ។

54. សហមេធាវីនាំមុខតវ៉ាពីដំបូងថា សំណើរបស់មេធាវីការពារក្ដីសុំឱ្យអង្គជំនុំជម្រះសាលាដំបូងពិចារណាឡើងវិញលើសេចក្ដីសម្រេចពាក់ព័ន្ធនឹងចម្លើយសារភាពរបស់ ជា ណុន ពុំបានធ្វើឡើងទាន់ពេលវេលា ហើយករណីដែលថា ចំណារនោះឃើញមាននៅលើឯកសារខ្មែរពិបាកថាជា "កាលៈទេសៈថ្មី" ណាស់ ដោយសារសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងត្រូវបានចេញអស់ជិតរយៈពេលមួយឆ្នាំមកហើយ[107]។ មេធាវីការពារក្ដីមានបំណងគ្រាន់តែចង្អុលបង្ហាញថា សំអាងហេតុលើសំណើរបស់ខ្លួនសុំឱ្យអង្គជំនុំជម្រះពិចារណាឡើងវិញគឺជាកំហុសជាក់ស្ដែងមួយនៅក្នុងសេចក្ដីសម្រេចដែលនឹងនាំឱ្យមានភាពអយុត្តិធម៌[108]។ម្យ៉ាងវិញទៀត ញត្តិរបស់មេធាវី

---

[104] ឯកសារ **E399/2** ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៨។

[105] ប្រ. ថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១៦ (ប្រាក់ ខន សេចក្ដីព្រាងប្រតិចារឹក) ទំព័រ ៤៧ ជួរទី៤-ទំព័រ ៤៨ ជួរទី ៤។

[106] ឯកសារ **E3/1892** ចម្លើយសារភាព ស-២១ របស់ ជា ណុន *ហៅ* សួង *សូមមើល* ខ. KH 00012699, 00012762-63, 00012795, 00012826, 00012832, 00012889, 00012911, 00012924, 00012944។ ក្របទំព័រនៃផ្នែកនីមួយៗតែងតែបញ្ចូលចំណងជើងដូចជា "ចម្លើយសារភាពរបស់ ជា ណុន *ហៅ* សួង កងពល ៤៥០" នៅលើក្របទំព័រ និងកាលបរិច្ឆេទនៅទំព័រខាងក្រោម។ ក៏ប៉ុន្ដែ ទំព័រមានចំណារដែលចោទជាបញ្ហានោះគ្មានចំណងជើង ឬ កាលបរិច្ឆេទនោះទេ។

[107] ឯកសារ **E399/1** ចម្លើយតបរបស់សហមេធាវីនាំមុខ កថាខណ្ឌ ២១។

[108] ឯកសារ **E399** សំណើសុំ កថាខណ្ឌ ១៤។

ការពារក្តីត្រូវបានធ្វើឡើងដោយសារតែសេចក្តីសម្រេចនាពេលថ្មីៗរបស់អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូលលើ "ភ័ស្តុតាងដែលបានទទួលមកពីទារុណកម្ម"។ ដូច្នេះ សំណើសុំនេះពុំបានដាក់ទាន់ពេលវេលាកំណត់នោះឡើយ។

55. បន្ទាប់មក សហមេធាវីនាំមុខតវ៉ាថា ចម្លើយសារភាពរបស់ ជា ណុន មានលក្ខណៈស៊ីសង្វាក់គ្នាជារួមនឹងការរកឃើញរបស់អង្គជំនុំជម្រះសាលាដំបូងថា មានការសេចក្តីណែនាំឱ្យសួរចម្លើយអ្នកជាប់ឃុំឡើងវិញរហូតដល់ពេលទទួលបានចម្លើយសារភាពរបស់ពួកគេទាំងស្រុង[109]។ មេធាវីការពារក្តីខកខានមិនបានមើលឃើញរបៀបដែល "ការសួរចម្លើយឡើងវិញ" អាចត្រូវបានចាត់ទុកថានាំឱ្យមានហានិភ័ជាក់ស្តែងនៃទារុណកម្មនោះទេ។ ឌុច បាននិយាយថា គាត់គឺជាបុគ្គលម្នាក់ដែលបានបញ្ជាឱ្យអ្នកសួរចម្លើយប្រើប្រាស់ "ទារុណកម្ម" នៅក្នុងពេលសួរចម្លើយបន្ថែម ហើយគាត់នឹងបញ្ជាដូច្នោះតាមរយៈចំណារលើចម្លើយសារភាពរបស់អ្នកជាប់ឃុំដើម្បីជាយោបល់ឱ្យប្រើប្រាស់ "ទារុណកម្ម"[110]។ ប៉ុន្តែ ករណីនេះមិនកើតឡើងចំពោះ ជា ណុន នោះទេ។ មានចំណារតែចំនួនពីរតែប៉ុណ្ណោះមកពី ឌុច ដែលឃើញមាននៅលើចម្លើយសារភាពរបស់ ជា ណុន ដែលចំណារមួយនោះផ្តល់ឱ្យយោបល់ឱ្យសួរចម្លើយបន្ថែម[111]។ យើងពុំឃើញមានការលើកឡើងអំពីការប្រើប្រាស់ "ទារុណកម្ម" នៅក្នុងចំណារណាមួយនោះឡើយ។ លើសពីនេះ ដូចបានពិភាក្សាខាងលើ (កថាខណ្ឌ ៥៤) ពាក្យ "ទារុណកម្ម" ដែលបានប្រើប្រាស់ដោយសាក្សីមិនអាចចាត់ទុកថាសំដៅជាក់លាក់លើអត្ថន័យតាមន័យផ្នែកច្បាប់ថាជាទារុណកម្មនោះទេ ដោយសារពាក្យ "ទារុណកម្ម" ជាភាសាខ្មែរមានអត្ថន័យទូលាយយ៉ាងខ្លាំង ហើយអាចសំដៅលើការប្រព្រឹត្តក្នុងកម្រិតមិនសូវធ្ងន់ធ្ងរ មិនមែនជាទារុណកម្មនោះទេ។

---

[109] ឯកសារ **E399/1** ចម្លើយតបរបស់សហមេធាវីនាំមុខ កថាខណ្ឌ ២២ ដែលយោងលើសាលក្រមលើសំណុំរឿង ០០១ កថាខណ្ឌ ១៧៦។

[110] ប្រ. ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០០៩ (កាំង ហ្កេកអ៊ាវ *ហៅ* ឌុច ឯកសារ **E3/5800**) ទំព័រ ៨៥ ជួរទី ២២-ទំព័រ ៨៦ ជួរទី ១។

[111] ឯកសារ **E3/1892** ចម្លើយសារភាព ស-២១ របស់ ជា ណុន *ហៅ* សួង *សូមមើល* ខ. KH 00012762, 00012843 (EN 00769598)។ ចំណារទីពីរសរសេរថា៖ "មិត្ត ប៊ុន ស្នើបញ្ជាក់អាសួងអំពោះឈ្មោះខ្លះដែលវាបានសរសេរក្នុងនេះហើយឱ្យច្បាស់នាទី និងច្បាស់កងអង្គភាព"។

56. សហមេធាវីនាំមុខក៏តវ៉ាផងដែរថា គុណភាពនៃរូបថតមិនអាចឲ្យប្រៀបធៀបឲ្យបានពិតប្រាកដជាមួយនឹងសំណោរនោះទេ[112]។ មេធាវីការពារក្ដីកត់សម្គាល់ឃើញថា នៅក្នុងសេចក្ដីសម្រេចដែលសហមេធាវីនាំមុខបានយោងនោះ អង្គជំនុំជម្រះសាលាដំបូងពុំបានច្រានចោលសំណើសុំធ្វើកោសលវិច័យដោយផ្អែកលើមូលដ្ឋានថា គុណភាពនៃសំណៅថតចម្លងពុំអាចមានគុណភាពល្អគ្រប់គ្រាន់នោះទេ។ ក៏ប៉ុន្ដែ អង្គជំនុំជម្រះបានច្រានចោលសំណើសុំនោះ ពីព្រោះការជួយជ្រោមជ្រែងពីអ្នកជំនាញ ពុំតម្រូវឲ្យធ្វើឡើង នៅក្នុងករណីជាក់លាក់នោះដើម្បីវាយតម្លៃថាតើចំណារដែលចោទជាបញ្ហាទាំងនោះត្រូវបានសរសេរដោយមនុស្សខុសៗគ្នាឬយ៉ាងណា[113]។ អង្គជំនុំជម្រះអាចនៅតែធ្វើការស៊ើបអង្កេតក្នុងការស្វែងរកសំណៅដើមនៃឯកសារនោះបាន ហើយនឹងបង្គាប់ឲ្យធ្វើកោសលវិច័យវិភាគបាន នៅពេលខ្លួនយល់ឃើញថាចាំបាច់ត្រូវការការជួយជ្រោមជ្រែងពីអ្នកជំនាញ។

57. សរុបរួមមក មេធាវីការពារក្ដីមានការភ្ញាក់ផ្អើលចំពោះភាពស្ទាក់ស្ទើររបស់សហមេធាវីនាំមុខក្នុងការអនុញ្ញាតឲ្យអង្គជំនុំជម្រះធ្វើកោសលវិច័យវិភាគដែលអាចមានសារៈសំខាន់ក្នុងការជួយបញ្ជាក់ដល់ការពិត។ កំហុសក្នុងការស្វែងរកយុត្តិធម៌ពុំមែនជាផលប្រយោជន៍របស់ភាគីណាមួយនោះទេ រួមទាំងដើមបណ្ដឹងរដ្ឋប្បវេណីដែលតំណាងដោយសហមេធាវីនាំមុខផងដែរ។

## V. សំណើសុំ

58. យោងតាមហេតុផលខាងលើ មេធាវីការពារក្ដីស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងច្រានចោលទឡ្ហីករណ៍ដែលបានលើកឡើងនៅក្នុងចម្លើយតបរបស់សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ហើយយល់ព្រមតាមសំណើរបស់មេធាវីការពារក្ដីសុំប្រើប្រាស់ចម្លើយសារភាពនៅ ស-២១ របស់ កុយ ធួន, យឹម សម្បត្តិ និង ជា ណុន។

---

[112] ឯកសារ **E399/1** ចម្លើយតបរបស់សហមេធាវីនាំមុខ កថាខណ្ឌ ២៣ ដែលដកស្រង់ ឯកសារ **E349/1** "សេចក្ដីសម្រេចលើសំណើរបស់ ខៀវ សំផន សុំឲ្យមានការវាយតម្លៃដោយអ្នកជំនាញលើឯកសារ **E3/2107**" ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ("សេចក្ដីសម្រេចរបស់ អ.ជ.ស.ដ លើការវាយតម្លៃដោយអ្នកជំនាញ")។

[113] ឯកសារ **E349/1** សេចក្ដីសម្រេចរបស់ អ.ជ.ស.ដ លើការវាយតម្លៃដោយអ្នកជំនាញ កថាខណ្ឌ ៥-៦។

**សហមេធាវីការពារក្តី នួន ជា**

**សុន អរុណ** Victor KOPPE